# ក្រសួងអប់រំតំបន់ឡុងប៊ិច/ផែនការអប់រំពិសេសប្រចាំតំបន់
# សិទ្ធិរបស់មាតាបិតានិងទម្រង់ការការពារ

# ការិយាល័យផ្តល់សេវាកម្មគាំទ្រដល់ការសិក្សា
# ផ្នែកអប់រំពិសេស

កែសម្រួលឡើងវិញ ខែមេសា ឆ្នាំ២០០៩

**Khmer Parents' Rights and Procedural Safeguards**
**Revised April 2009**

# ក្រសួងអប់រំតំបន់ឡុងប៊ីច/ផែនការអប់រំពិសេសប្រចាំតំបន់
# សិទ្ធិរបស់មាតាបិតានិងទម្រង់ការការពារ

## អ្នកផ្លូវការផ្នែកការប្រព្រឹត្តឱ្យស្របតាមច្បាប់

Connie L. Jensen
អនុអគ្គនាយក
ការិយាល័យផ្តល់សេវាកម្មគាំទ្រដល់ការសិក្សា
ផ្នែកអប់រំពិសេស
1515 Hughes Way
Long Beach, CA 90810
ទូរស័ព្ទ: (562) 997-8644

## អភិបាលនៃកម្មវិធីអប់រំពិសេស

Parisima Shahidi
1515 Hughes Way
Long Beach, CA 90810
ទូរស័ព្ទ: (562) 997-8051

## អ្នកទុកដាក់ថែរក្សាសំណុំរឿង

Richard M. Tebbano
អភិបាល
2221 Argonne Ave.
Long Beach, CA 90815
ទូរស័ព្ទ:(562) 986-6870 X 240

## សមាជិកក្រុមប្រឹក្សាភិបាលក្រសួងអប់រំ

Jon Meyer, ប្រធាន

Mary Stanton, អនុប្រធាន

Felton Williams, សមាជិក

David Barton, សមាជិក

Michael Ellis, សមាជិក

## អគ្គនាយកសាលា

Christopher Steinhauser

# មាតិការរឿង


អត្ថន័យ………………………………………….……………......…….4

បណ្ណសារសិក្សា…………………………….……………...........……5

ការស្ទង់ប្រមាណដោយភាគីទីបី…................……………………………....7

ការជូនដំណឹងជាលាយលក្ខណ៏អក្សរជាមុន………...............................…8

ការយល់ព្រមរបស់មាតាបិតា………………….…………………….…...8

ការដកហូតវិញនូវការយល់ព្រម……………...…..……………………....8

ទម្រង់ការក្នុងការបណ្ដឹងត៏វ៉ា…………………......……………….......9

ការដោះស្រាយជំទាស់ដោយសម្រុះសម្រួលគ្នា (ADR)…….……..9

ការនាំសម្រុះសម្រួល…………………….……………….…..…10

រឿងក្ដី……………………………….……........………… 11

ថ្ងៃឈ្នួលមេធាវី……………………………………....……..13

ការដាក់ពិន័យ……………………………............……………13

ការដាក់ឲ្យរៀនជាបណ្ដោះអាសន្ន………….........................…..14

ឯកតោភាគីក្នុងការដាក់ឲ្យរៀនសាលាឯកជន……..................……...15

សាលារៀនពិសេសរបស់រដ្ឋ……...............................………………15

ឳពុកម្ដាយចិញ្ចឹម……………………...................................……15

*ជូនចំពោះមាតាបិតា អ្នកអាណាព្យាបាល និងសិស្ស:*

សេចក្តីប្រកាសនេះបានផ្តល់ឲ្យលោកអ្នកពីព្រោះកូនរបស់លោកអ្នកត្រូវបានចាត់ទុកសំរាប់ដាក់ឲ្យរៀនក្នុងកម្មវិធីសិក្សាណាមួយ ឬទើបតែចុះឈ្មោះនៅក្នុងកម្មវិធីអប់រំពិសេសមួយ។ សេចក្តីប្រកាសនេះក៏ផ្តល់ផងដែរសំរាប់សិស្សដែលអាចទទួលសិទ្ធិទាំងនេះ គ្រប់អាយុ១៨ឆ្នាំ។ បើកូនរបស់លោកអ្នកត្រូវបានបញ្ជូនឲ្យទៅរៀនក្នុងកម្មវិធីអប់រំពិសេស ហើយជំរើសគ្រប់ផ្នែកនៃកម្មវិធីអប់រំធម្មតាបានត្រូវគិតគូមើលដោយសមរម្យសំរាប់កូនរបស់លោកអ្នករួចហើយ លោកអ្នកមានសិទ្ធិដើម្បីចាប់ផ្តើមការសុំឲ្យកូនបានទទួលការអប់រំពិសេស។

នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា ការអប់រំពិសេសត្រូវបានផ្តល់ឲ្យចំពោះកុមារអសមត្ថភាពអាយុពីកំណើតរហូតដល់២១ឆ្នាំ។ ច្បាប់របស់សហព័ន្ធនិងរបស់រដ្ឋ ការពារកូនរបស់លោកអ្នកទូទាំងទំរង់ការសំរាប់ការវិនិច្ឆ័យនិងអត្តសញ្ញាណកម្មនៃការ ដាក់ចូលនិងការផ្តល់សេវាកម្ម នៃការអប់រំពិសេស។ មាតាបិតានៃសិស្សដែលមានភាពពិការមានសិទ្ធិចូលរួមនៅក្នុងដំណើរការកម្មវិធីអប់រំផ្ទាល់ខ្លួន(IEP) នឹងត្រូវបានឲ្យដឹងពីកម្មវិធីសិក្សាដែលមានផ្តល់ឲ្យពីការអប់រំសាធារណៈដោយឥតគិតថ្លៃ (FAPE) និងការផ្តល់ឲ្យកម្មវិធីផ្សេងទៀតរួមមានជាសាធារណៈនិងឯកជន។

លោកអ្នកមានសិទ្ធិដើម្បីទទួលសេចក្តីប្រកាសនេះជាភាសាកំណើតរបស់លោកអ្នកឬទំនាក់ទំនងផ្សេងទៀតដូចជាភាសាសញ្ញាឬភាសាគរលើកលែងតែវាច្បាស់ថាមិនអាចធ្វើដូច្នេះបាន។ សិទ្ធិទាំងនេះក៏អាចបកប្រែដោយផ្ទាល់មាត់ជូន លោកអ្នកដែរប្រសិនបើភាសាកំណើតរបស់លោកអ្នកមិនមែនជាភាសាសរសេរ។ សេចក្តីប្រកាសនេះនឹងផ្តល់ជូនលោកអ្នកតែម្តងគត់ក្នុង១ឆ្នាំ ឬនៅពេល (១)លោកអ្នកស្នើសុំ (២)ការបញ្ជូនកូនលោកអ្នកដើម្បីធ្វើការស្ទង់ប្រមាណជាលើកទីដំបូង (៣)ការស្ទង់ប្រមាណកូនលោកអ្នកឡើងវិញ (៤)ការដកកូនលោកអ្នកចេញពីកម្មវិធីអប់រំពិសេសដោយកូនលោកអ្នកបានបំពានលើវិន័យសាលាហើយដែលបង្កបង្កើតជាការផ្លាស់ប្តូរកម្មវិធីអប់រំ (៥)ការដាក់ពាក្យបណ្តឹងតវ៉ាជាមួយរដ្ឋ និងទី(៦)ការបានទទួលសំណើសវនាការរឿងក្តី។ ច្បាប់ចំលងនៃទំរង់ការការពារនេះក៏មាននៅក្នុងវែបសាយរបស់ក្រសួងអប់រំផងដែរ។

អត្ថន័យខាងក្រោមនេះនឹងជួយលោកអ្នកឲ្យយល់ពីសិទ្ធិរបស់លោកអ្នក។ បើសិនជាលោកអ្នកត្រូវការពត៌មានបន្ថែមទៀតស្តីពីមាតិការ ឬការប្រើប្រាស់ឯកសារនេះ លោកអ្នកអាចទាក់ទងអភិបាលនៃការអប់រំពិសេសដែលមានលេខទូរសព្ទ័នៅលើទំព័រទី២នៃឯកសារនេះ។

## *Definitions*

***កុមារដែលមានអសមត្ថភាព:*** ច្បាប់អប់រំសម្រាប់បុគ្គលដែលមានអសមត្ថភាព The Individuals with Disabilities Education Act (IDEA) ឲ្យអត្ថន័យថា “កុមារដែលមានអសមត្ថភាព” ដែលរួមមានកុមារអសមត្ថភាពខាងបញ្ញា ស្តាប់មិនសូវលឺរួមទាំងពិការត្រចៀក និយាយមិនសូវច្បាស់ មើលមិនសូវឃើញរួមទាំងពិការភ្នែក ខូចសតិ ខ្វិនដៃជើង ខូចខួរក្បាល របួសធ្ងន់ខាងខួរក្បាល ការខូចខាតខាងសុខភាពដ៏ទៃទៀតឬអសមត្ថភាពសិក្សាខាងវិជ្ជាណាមួយ និងជាកុមារដែលដោយមូលហេតុណាមួយ ត្រូវការការអប់រំពិសេសនិងសេវាកម្មផ្សេងៗទៀត។

***ការយល់ព្រម:*** ការយល់ព្រមមានន័យថា: (១)មាតាបិតាត្រូវបានផ្តល់ព័ត៌មានទាំងអស់នៅក្នុងភាសាកំណើតរបស់គាត់ ឬតាមវិធីធ្វើទំនាក់ទំនងផ្សេងទៀត ដែលទាក់ទងទៅនឹងសកម្មភាពអ្វីមួយដែលត្រូវការការយល់ព្រមរបស់គាត់ (២)មាតាបិតាបានយល់ហើយបានយល់ព្រមជាលាយលក្ខណ៍អក្សរទៅលើសកម្មភាពនោះ ហើយក្រដាសយល់ព្រមដែលគាត់បានចុះហត្ថលេខាមានពណ៌នាអំពីសកម្មភាពហើយនិងបណ្ណសារដែលត្រូវផ្តល់ឲ្យអ្នកដែលត្រូវបានទទួលបណ្ណសារដើម្បីចាប់ផ្តើមឬការដាក់ប្រតិបត្តិនូវសកម្មភាព ហើយ(៣)មាតាបិតាយល់ដឹងថាការយល់ព្រមរបស់គាត់គឺធ្វើឡើងដោយស្ម័គ្រចិត្តហើយគាត់អាចដកហូតវិញបាននៅពេលណាក៏បាន ក៏ប៉ុន្តែការដកហូតនូវការយល់ព្រមរបស់គាត់មិនមែនជាការបដិសេធទៅលើសកម្មភាពណាមួយដែលបានដាក់ប្រតិបត្តរួចទៅហើយនោះទេ។

***ការស្ទង់ប្រមាណ:*** ការស្ទង់ប្រមាណទៅលើកូនលោកអ្នកដោយប្រើតែស្តនិងវិធានការផ្សេងៗទៅតាមច្បាប់ការអប់រំផ្នែកលេខ៥៦៣២០-៥៦៣៣៩និង២០ U.S.C. ផ្នែកលេខ1414(a) (b)និង (c) ដើម្បីសន្និដ្ឋានថាកូនលោកអ្នកមានអសមត្ថភាព ហើយដើមកំណើតនិងទំហំនៃសេវាកម្មពិសេសដែលកូនលោកអ្នកត្រូវការសំរាប់ប្រយោជន៍នៃការសិក្សារបស់គេ។ វិធីស្ទង់ប្រមាណត្រូវបានជ្រើសរើសត្រឹមត្រូវសំរាប់កូនលោកអ្នក និងត្រូវបានពិនិត្យដោយអ្នកដែលមានសមត្ថភាពខាងវិជ្ជាជីវៈធ្វើការនៅក្នុងក្រសួងអប់រំក្នុងស្រុក។ សម្ភារៈនិងទំរង់ការប្រឡងនិងវិនិច្ឆ័យនឹងត្រូវបានជ្រើសរើសនិងផ្តល់ឲ្យដោយមិនប្រកាន់ប្រកាន់ពូជសាសន៍និងទំនៀមទំលាប់។ សម្ភារៈ និងទំរង់ការនឹង

ត្រូវផ្តល់ឲ្យនៅក្នុងភាសាកំណើតរបស់កូនលោកអ្នកឬតាមរបៀបទំនាក់ទំនងផ្សេងទៀតលើកលែងតែវាបញ្ជាក់យ៉ាងច្បាស់ថាមិនអាចធ្វើទៅរួច។ គ្មានទំរង់ការណា១ដែលគួរតែជាលក្ខណវិនិច្ឆ័យតែ១គត់សំរាប់សំរេចកម្មវិធីសិក្សាដ៏សមរម្យសំរាប់កុមារម្នាក់ឡើយ។

***ការទទួលការអប់រំសាធារណៈដោយទទេហើយត្រឹមត្រូវ(FAPE)*** ជាការអប់រំដែល (១)ផ្តល់ឲ្យជាការចំណាយរបស់រដ្ឋ នៅក្រោមការមើលខុសត្រូវនិងដឹកនាំដោយរដ្ឋ និងមិនគិតថ្លៃចំពោះលោកអ្នក (២)ធ្វើតាមខ្នាតគំរូរបស់ក្រសួងអប់រំរបស់រដ្ឋកាលីហ្វ័រនីញ៉ា និង(៣) ផ្តល់ឲ្យ យោងតាមកម្មវិធីអប់រំផ្ទាល់ខ្លួន (IEP) ដែលបានធ្វើឡើងសំរាប់កូនលោកអ្នកដើម្បីឲ្យបានទទួលផលប្រយោជន៏នៃការសិក្សា១ និងដើម្បីប្រតិបត្តិនៅក្នុងកម្មវិធីសិក្សានៅបុរេសាលា បឋមសិក្សា ឬសាលាវិទ្យាល័យរបស់រដ្ឋ។

***កម្មវិធីអប់រំផ្ទាល់ខ្លួន(IEP):*** ជាឯកសារ១ដែលបានធ្វើឡើងដោយក្រុមអ្នកចាត់ចែងកម្មវិធីអប់រំផ្ទាល់ខ្លួនរបស់កូនលោកអ្នកដែលមានរួមបញ្ចូលនូវអ្វីៗទាំងអស់ខាងក្រោមនេះ (១)កំរឹតចំណេះខាងការសិក្សានិងខាងការចេះដឹងទូទៅបច្ចុប្បន្ន (២)គោលដៅប្រចាំឆ្នាំដែលសមរម្យទៅតាមលទ្ធភាពសិស្ស (៣)ផែនការអប់រំពិសេសនិងសេវាកម្មព្រមទាំងជំនួយបន្ថែមផ្សេងៗទៀត យោងតាមការសិក្សាស្រាវជ្រាវដែលសមរម្យសម្រាប់ប្រតិបត្តិដាក់ផែនការអប់រំសម្រាប់កូនលោកអ្នក (៤)ការពន្យល់ប្រាប់អំពីកំរឹតនៃការសិក្សាដែលកូនលោកអ្នកនឹងមិនចូលរួមជាមួយសិស្សដែលពុំមានអសមត្ថភាពនៅក្នុងកម្មវិធីសិក្សាជាធម្មតា (៥)ថ្ងៃខែដែលគំរោងទុកសំរាប់ការចាប់ផ្តើមនិងកំឡុងរយៈពេល ភាពញឹកញាប់ និងទីកន្លែងនៃកម្មវិធីនិងសេវាកម្មដែលដាក់នៅក្នុងកម្មវិធីអប់រំផ្ទាល់ខ្លួន និង(៦)លក្ខ័ណៈវិនិច្ឆ័យនៃគោលដៅដ៏សមរម្យ ទំរង់ការស្ទង់ប្រមាណ និងតារាងពេលសំរាប់ការសំរេច យ៉ាងតិចមួយឆ្នាំម្តង ទោះជាសិស្សរៀនបានលិទ្ធផលដូចគោលដៅដែររឺអត់ក៏ដោយ។

***បរិយាកាសដែលមានកំរឹតតិចបំផុត (LRE):*** ទៅតាមភាពសមរម្យដ៏ខ្ពស់ជាងគេ កុមារដែលមានអសមត្ថភាពនឹងត្រូវបានអប់រំជាមួយកុមារដែលមិនមានអសមត្ថភាព និងថ្នាក់ពិសេស សាលាខុសគ្នា ឬការយកកុមារដែលមានអសមត្ថភាពចេញពីកម្មវិធីអប់រំទូទៅនឹងកើតឡើងនៅពេលដើមកំណើតឬភាពធ្ងន់ធ្ងរនៃអសមត្ថភាពដែលថាការអប់រំនៅក្នុងថ្នាក់ទូទៅដោយប្រើជំនួយបន្ថែមនិងសេវាផ្សេងៗមិនអាចទទួលបានដោយពេញចិត្ត។

***ក្រសួងអប់រំក្នុងតំបន់(LEA):*** ពាក្យនេះមានរួមទាំងក្រសួងអប់រំ ការិយាល័យអប់រំប្រចាំខេានធី (COE), ផែនការអប់រំពិសេសប្រចាំតំបន់ (SELPA) ឬសាខាសាលារៀន១ដែលចូលរួមជាសមាជិករបស់ SELPA ។

***ការជូនដំណឹងអំពីសិទ្ធិធំៗ:*** កូនរបស់លោកអ្នកមានសិទ្ធិទទួលព័ត៏មានទាំងអស់អំពីកម្មវិធីអប់រំរបស់ពួកគេនិងធ្វើការសំរេចចិត្តទាំងអស់នៅពេលគេមានអាយុ១៨ឆ្នាំលើកលែងតែច្បាប់និងទំរង់ការរបស់រដ្ឋយល់ឃើញថាខ្វះសមត្ថភាពក្នុងការសម្រេចចិត្តអ្វីមួយ។ មនុស្សពេញវ័យណាដែលពុំមានអ្នកតំណាង ត្រូវបានសន្មតតាមច្បាប់កាលីហ្វ័រនីញ៉ាថាមានសមត្ថភាពនិងធ្វើការសម្រេចចិត្តអ្វីមួយ។

***មាតាបិតា:*** អត្ថន័យរបស់ពាក្យមាតាបិតា គឺ (១)បុគ្គលណាដែលមានសិទ្ធិពេញច្បាប់ក្នុងការមើលថែរក្សាកុមារ (២)សិស្សពេញវ័យណាម្នាក់ដែលពុំមានអ្នកអាណាព្យាបាលឬអ្នកតំណាងណាម្នាក់ដែលបានតែងតាំងជំនួយ (៣) បុគ្គលណាម្នាក់ដែលតំណាងជំនួសមាតាបិតាបង្កើតឬចិញ្ចឹម ដូចជាជីដូនជីតា មាតាបិតាចុង ឬសាច់ញាតិណាដែលសិស្សរស់នៅជាមួយ (៤)មាតាបិតាដែលបានតែងតាំងដោយច្បាប់ (៥)មាតាបិតាធម៌ បើសិនជាតុលាការបានបញ្ជាថាមាតាបិតាបង្កើតរបស់សិស្សពុំមានសិទ្ធិក្នុងការសម្រេចចិត្តទៅលើការសិក្សារបស់សិស្សនោះទេ។

## តើនៅពេលណាដែលខ្ញុំអាចពិនិត្យមើលបណ្ណសារសិក្សាបាន និងតើខ្ញុំអាចពិនិត្យមើលដោយវិធីណា?

មាតាបិតាឬអ្នកអាណាព្យាបាលទាំងអស់នៃកុមារដែលចុះឈ្មោះរៀននៅក្នុងសាលរៀនសាធារណៈក្នុងរដ្ឋកាលីហ្វ័រនីញ៉ា មានសិទ្ធិពិនិត្យមើលបណ្ណសារសិក្សាយោងតាមច្បាប់អប់រំ "សិទ្ធិរបស់គ្រួសារក្នុងការសិក្សានិងភាពឯកជន" ដែលត្រូវបានប្រតិបត្តិនៅក្នុងច្បាប់អប់រំរបស់រដ្ឋកាលីហ្វ័រនីញ៉ា។

បណ្ណសារសិក្សាគឺជាឯកសារទាំងឡាយដែលទាក់ទងផ្ទាល់ទៅនឹងកូនសិស្សនិងរក្សាទុកឲ្យដោយក្រសួងអប់រំ អង្គការ ឬវិជ្ជាស្ថានណាមួយដែលប្រមូល រក្សា ឬប្រើប្រាសព័ត៏មានដែលអាចធ្វើការកំណត់សំគាល់អត្តសញ្ញាណ ឬពីកន្លែងដែលអាចរកព័ត៏មាននោះបាន។ ទាំងច្បាប់សហព័ន្ធនិងច្បាប់រដ្ឋបានឲ្យអត្ថន័យបណ្ណសារសិក្សាថាជាព័ត៏មានណាដែលទាក់ទងផ្ទាល់ទៅនឹងការសំគាល់អត្តសញ្ញាណសិស្សហើយដែលមិនជាព័ត៏មានសម្រាប់រកមើលឈ្មោះនិងទីលំនៅ ដែលរក្សាទុកដោយក្រសួងអប់រំក្នុងតំបន់ ឬតំរូវឲ្យថែរក្សាដោយបុគ្គលិកម្នាក់នៅក្នុងការធ្វើភារកិច្ចរបស់គាត់ទោះជាចំលងដោយដៃ អក្សរពុម្ព កាសែតស្តាប់ មីក្រូហ្វីលម៍ កុំព្យូទ័រឬដោយវិធីផ្សេងៗទៀត។

បណ្ណសារសិក្សាពុំមានដាក់បញ្ចូលនូវសារខ្មីៗផ្ទាល់ខ្លួនក្រៅផ្លូវការដែលបានរៀបចំនិងរក្សាដោយបុគ្គលិកសាលាណាម្នាក់សំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់គាត់ឬប្រើសំរាប់អ្នកជំនួសទេ។ បើបណ្ណសារសិក្សាមានពត៌មានអំពីសិស្សលើសពីម្នាក់ លោកអ្នកមានសិទ្ធិពិនិត្យមើលតែ ចំណែកបណ្ណសាររបស់កូនលោកអ្នកប៉ុណ្ណោះ។

ព័ត៌មានជាអត្តសញ្ញាណអាចមាននូវ (១)ឈ្មោះរបស់សិស្ស មាតាបិតារបស់សិស្សឬសមាជិកក្នុងគ្រួសារ (២)អាស័យដ្ឋានរបស់សិស្ស (៣)កំណត់អត្តសញ្ញាណផ្ទាល់ខ្លួន ដូចជាលេខសន្តិស្ខុយសង្គ្រោះ លេខសិស្ស ឬលេខបញ្ជីតុលាការ (៤)កំណត់ភិនភាគរបស់សិស្សឬព័ត៌មានអ្វីមួយដែលអាចប្រើប្រាសក្នុងការកត់សម្គាល់អត្តសញ្ញាណរបស់សិស្ស។

ថែមពីនោះទៀត មាតាបិតានៃសិស្សអសមត្ថិភាព រួមទាំងមាតាបិតាដែលពុំមានសិទ្ធិមើលថែរក្សាកុមារហើយដែលនៅមានសិទ្ធិក្នុងការសិក្សារបស់សិស្ស ត្រូវបានសន្មតថាមានសិទ្ធិនឹង (១)ពិនិត្យមើលគ្រប់បណ្ណសារសិក្សាទាំងអស់ស្តីពីការកត់សម្គាល់ ការស្ទង់ប្រមាណនិងការចាត់ដាក់ឲ្យសិស្សរៀន និង(២)បានទទួលការពន្យល់និងការបកស្រាយទៅលើបណ្ណសារសិក្សា។ សិទ្ធិទាំងនេះត្រូវផ្ទេរទៅសិស្សដែលពុំមានអ្នកតំណាងដែលមានអាយុ១៨ឆ្នាំឬដែលទៅរៀននៅសាលាណាមួយបន្ទាប់ពីសាលាវិទ្យាល័យ។

អ្នកថែរក្សាឯកសារនៅសាលាមួយៗគឺជានាយកសាលា។ អ្នកថែរក្សាឯកសារសម្រាប់ក្រសួងអប់រំនិមួយៗដែលស្ថិតនៅក្នុង SELPA មានរាយឈ្មោះនៅទំព័រទី២នៃឯកសារនេះ។ បណ្ណសារសិក្សាសិស្សអាចរក្សាទុកនៅសាលាឬការិយាល័យក្រសួងអប់រំ ប៉ុន្តែការស្នើសុំជាលាយលក្ខណ៏អក្សរនៅកន្លែងណាមួយនឹងចាត់ទុកថាជាការស្នើសុំពីកន្លែងទាំងអស់។ អ្នកថែរក្សាឯកសារនឹងផ្តល់ឲ្យលោកអ្នកនូវប្រភេទនិងទីកន្លែងនៃឯកសាររបស់កុមារ(បើស្នើសុំ)។ ៣ឆ្នាំបន្ទាប់ពីសិស្សចេញពីកម្មវិធី ឯកសារការអប់រំពិសេសនឹងត្រូវបំផ្លាញ។

អ្នកថែរក្សាឯកសារនឹងដាក់កំរិតការឲ្យមើលទៅបណ្ណសារសិក្សារបស់កូនលោកអ្នកទៅដល់តែបុគ្គលណាដែលបានអនុញ្ញាតឲ្យពិនិត្យឯកសារសិក្សារបស់សិស្សដែលរួមទាំងលោកអ្នក កូនលោកអ្នកដែលមានអាយុយ៉ាងតិច១៦ឆ្នាំ បុគ្គលដែលបានអនុញ្ញាតដោយលោកអ្នកឲ្យពិនិត្យមើលឯកសារ បុគ្គលិករបស់សាលាដែលមានចំណែកក្នុងការអប់រំ គ្រឹះស្ថានអប់រំបន្ទាប់ពីវិទ្យាល័យដែលបានជ្រើសរើសដោយកូនលោកអ្នក និងបុគ្គលិករបស់រដ្ឋាភិបាល រដ្ឋ និង ក្រសួងអប់រំក្នុងស្រុក។ នៅក្នុងករណីដ៏ទៃទៀត ការបើកឲ្យពិនិត្យឯកសារនឹងត្រូវបដិសេធលើកលែងតែលោកអ្នកបានផ្តល់ឲ្យការយល់ព្រមជាលាយលក្ខណ៏អក្សរ ដើម្បីឲ្យបញ្ចេញឯកសារឬឯកសារត្រូវបានចេញឲ្យអនុលោមទៅតាមសេចក្តីបញ្ជារបស់តុលាការ។ LEA នឹងត្រូវកត់ទុកជាកំណត់ នូវពេលវេលា ឈ្មោះនិងគោលបំណងសំរាប់ការសុំពិនិត្យនៃបុគ្គលណាដែលមិនមែនជាបុគ្គលិករបស់ក្រសួងអប់រំ។

ការយល់ព្រមពីមាតាបិតាពុំចាំបាច់ទេមុននឹងផ្តល់ព័ត៌មានកត់សម្គាល់អត្តសញ្ញាណទៅឲ្យអ្នកផ្លូវការរបស់អង្គការណាមួយសម្រាប់ការតំរូវទៅតាមការតំរូវរបស់ IDEA ។ ការយល់ព្រមពីមាតាបិតាគឺចាំបាច់ក្នុងការចែកចាយព័ត៌មាននៅក្នុងកាលៈទេសៈខាងក្រោមនេះ

១) ប្រសិនបើសិស្សកំពុងរៀន ឬនឹងទៅរៀននៅសាលាឯកជនដែលមិនស្ថិតនៅក្នុង LEA នៃលំនៅដ្ឋានរបស់មាតាបិតា ការយល់ព្រមត្រូវតែមានមុននឹងបញ្ចេញព័ត៌មានសម្គាល់អត្តសញ្ញាណសិស្សរវៀងអ្នកផ្លូវការនៅក្នុង LEA ដែលសាលាឯកជននោះស្ថិតនៅក្នុង និងអ្នកផ្លូវការនៅក្នុង LEA នៃលំនៅដ្ឋានរបស់មាតាបិតា។ ច្បាប់អប់រំលេខ 20USC 1412(a)(8); 20 USC 1417(c); 34 CFR 300.622(b)(3)
២) មុននឹងបញ្ចេញព័ត៌មានសម្គាល់អត្តសញ្ញាណសិស្សរវៀងអ្នកផ្លូវការនៅក្នុងអង្គការដែលមានចំណែកក្នុងការសិក្សារបស់សិស្ស ឬចេញថ្លៃឈ្នួលសម្រាប់សេវាកម្មផ្ទេរការសិក្សា។

ការពិនិត្យមើលនិងច្បាប់ចំលងនៃឯកសារសិក្សានឹងត្រូវបានផ្តល់ឲ្យលោកអ្នកនៅក្នុងរយៈពេល៥ថ្ងៃនៃសេចក្តីស្នើសុំ។ ថ្លៃឈ្នួលសំរាប់ចំលងត្រូវបានកំណត់ដោយ LEA និងត្រូវគិតថ្លៃ លើកលែងតែការគិតថ្លៃអាចប៉ះពាល់ដល់ការបដិសេធឲ្យមើលទៅដល់មាតាបិតា។ នៅពេលដែលច្បាប់ឯកសារពេញលេញត្រូវបានប្រគល់ឲ្យ ការគិតថ្លៃនឹងធ្វើឡើងសំរាប់ការធ្វើច្បាប់ចំលងបន្ថែមនៃឯកសារដូចគ្នា។

នៅពេលណាបានទទួលដំណឹងថាបណ្ណសារលែងត្រូវការចំពោះ LEA លោកអ្នកអាចស្នើសុំឲ្យគេកំទេចចោលបណ្ណសារនោះ ដែលនឹងធ្វើឡើងដោយកំទេចចោលនូវបណ្ណសារឬលុបចេញនូវព័ត៌មានផ្ទាល់ខ្លួនពីបណ្ណសារ ដូច្នេះព័ត៌មាននោះមិនអាចរកអត្តសញ្ញាណឃើញ។ ក៏ប៉ុន្តែ LEA ត្រូវបានតំរូវឲ្យរក្សាជាអាចិន្ត្រៃនូវបណ្ណសាររបស់សិស្សម្នាក់ៗ ដែលមានរួមទាំង (១)ឈ្មោះ អាស័យដ្ឋាននិងលេខទូរស័ព្ទរបស់សិស្ស (២)កំរិតថ្នាក់របស់សិស្ស ប្រវត្តវត្តមាន វត្តមាននៅថ្នាក់ ថ្នាក់ដែលសិស្សបានបញ្ចប់ និងឆ្នាំដែលបានរៀនចប់។

បើលោកអ្នកជឿថាព័ត៌មាននៅក្នុងបណ្ណសារសិក្សាដែលបានប្រមូល ថែរក្សា ឬប្រើប្រាស់ដោយ LEA ពុំមានភាពត្រឹមត្រូវ នាំឲ្យយល់ខុស ឬរំលោភលើច្បាប់ផ្ទាល់ខ្លួនឬច្បាប់ដ៏ទៃទៀតរបស់កូនលោកអ្នក លោកអ្នកអាចស្នើសុំឲ្យ LEA កែសំរួលនូវព័ត៌មាននោះ។ បើ LEA ព្រមព្រៀង ឯកសារនឹងត្រូវកែប្រែហើយលោកអ្នកនឹងត្រូវប្រាប់ឲ្យដឹង។

បើ LEA បដិសេធធ្វើការកែប្រែដែលបានស្នើសុំក្នុងកំឡុងពេល៣០ថ្ងៃ LEA នឹងជូនដំណឹងដល់លោកអ្នកអំពីសិទ្ធិក្នុងការធ្វើសវនាការដើម្បីសំរេចថាតើពត៌មាននោះមិនត្រឹមត្រូវ នាំឲ្យយល់ខុស ឬរំលោភលើច្បាប់ផ្ទាល់ខ្លួនឬច្បាប់ដ៏ទៃទៀតរបស់កូនលោកអ្នក បើលោកអ្នកបានស្នើសុំឲ្យមានសវនាការ LEA នឹងផ្តល់សវនាការតាមពេលវេលាសមរម្យ ដែលស្របទៅតាមតំរូវការទាំងឡាយខាងក្រោមនេះ: (១) LEA ត្រូវផ្តល់ឲ្យលោកអ្នកដឹងជាមុននូវថ្ងៃខែ ម៉ោង និងទីកន្លែងនៃសវនាការ (២)សវនាការអាចធ្វើឡើងដោយបុគ្គលណាម្នាក់រួមទាំងអ្នកផ្លូវការរបស់ LEA ដែលពុំមានទាក់ទងអ្វីទៅលើលិទ្ធផលនៃសវនាការនេះ (៣) LEA ត្រូវតែផ្តល់ឱកាសគ្រប់គ្រាន់និងត្រឹមត្រូវដើម្បីឲ្យលោកអ្នកបង្ហាញភស្តុតាងផ្សេងៗដែលទាក់ទងទៅនឹងរឿងរ៉ាវ (៤) LEA ត្រូវធ្វើការសម្រេចចិត្តជាលាយលក្ខណ៏អក្សរនៅក្នុងរយៈពេលសមរម្យបន្ទាប់ពីសវនាការ និង(៥)ការសម្រេចចិត្តគឺធ្វើឡើងយោងទៅលើភស្តុតាងដែលបានបង្ហាញនៅក្នុងសវនាការ ហើយត្រូវមាននូវសេចក្តីសង្ខេបទៅលើភស្តុតាងហើយនិងមូលហេតុនៃការសម្រេចចិត្តនោះ។ លោកអ្នកអាច ដោយចំណាយខ្លួនឯង មានជំនួយឬមានអ្នកតំណាងជាជំរើសណាម្នាក់របស់លោកអ្នក គឺរួមទាំងមេធាវីផងដែរ។

បន្ទាប់ពីសវនាការ បើសិនជាក្រុមប្រឹក្សាគ្រប់គ្រងបានសម្រេចថា ឯកសានឹងមិនត្រូវកែប្រែអ្វីទេ លោកអ្នកមានសិទ្ធិផ្តល់ឲ្យនូវអ្វីដែលលោកអ្នកជឿជាក់ថាគឺជាការសរសេរកែកំហុស ដែលនឹងភ្ជាប់ទៅនឹងឯកសាជាអចិន្ត្រៃ។ សេចក្តីថ្លែងរបស់មាតាបិតានឹងភ្ជាប់បើសិនជាឯកសាដែលត៉វាបានបញ្ចេញឲ្យឃើញ។

### *អ្វីជាការស្ទង់ប្រមាណលើការសិក្សាជាឯករាជ្យ ហើយខ្ញុំអាចធ្វើទៅបានដោយរបៀបណា ?*

ការស្ទង់ប្រមាណលើការសិក្សាជាឯករាជ្យ("IEE") គឺជាការស្ទង់ប្រមាណមួយដែលធ្វើឡើងដោយអ្នកពិនិត្យធ្វើវិភាគប្រកបដោយមានសមត្ថភាព ដែលមិនមែនជាបុគ្គលដែលជួលដោយ LEA សំរាប់ផ្តល់ការអប់រំដល់កូនរបស់អ្នកឡើយ ប៉ុន្តែបំពេញរាល់លក្ខណ:សម្បត្តិទាំងអស់តំរូវដោយមន្ទីរអប់រំរដ្ឋ California ("CDE") និង LEA ។ បើសិនជាលោកអ្នកបដិសេធចំពោះលទ្ធផលនៃការស្ទង់ប្រមាណថ្មីៗរបស់ LEA ហើយលោកអ្នកបានផ្តល់ដំណឹងនេះដល់ LEA លោកអ្នកមានសិទ្ធិស្នើសុំ ហើយអាចនឹងទទួល IEE ពីបុគ្គលណាម្នាក់ដែលមានសមត្ថភាពដោយប្រើប្រាស់ចំណាយសាធារណ: ។ ចំណាយសាធារណ:មានន័យថា ទីភ្នាក់ងារសាធារណ:អាចនឹងទូទាត់តំលៃសរុបនៃការស្ទង់ប្រមាណឲ្យលោកអ្នក ឬធានាថាការស្ទង់ប្រមាណនេះគឺធ្វើឡើងដោយមិនគិតថ្លៃពីលោកអ្នកឡើយ ។ LEA របស់ លោកអ្នក មានពត៌មានផ្តល់ដល់លោកអ្នកអំពីកន្លែងដែលលោកអ្នកអាចទទួលបាន IEE និងពត៌មានអំពីរាល់លក្ខន្តិក:របស់ LEA សំរាប់កំណត់លក្ខណ:សម្បត្តិក្នុងការទទួលបាន IEE នោះ ។

ប្រសិនបើលោកអ្នកស្នើសុំ IEE ដោយប្រើប្រាស់ចំណាយសាធារណ: LEA អាច (១)ដាក់ពាក្យបណ្តឹងរឿងក្តីប្រឆាំងនឹងលោកអ្នកដើម្បីបង្ហាញថា ការស្ទង់ប្រមាណរបស់ខ្លួនគឺត្រឹមត្រូវ ឬ (២)ធានាថា IEE នឹងត្រូវបានផ្តល់ជូនដល់លោកអ្នកដោយប្រើប្រាស់ប្រាក់សាធារណ: ។ ប្រសិន បើ LEA បានបង្ហាញក្នុងសវនាការសេវាអប់រំថា ការស្ទង់ប្រមាណរបស់ខ្លួនពិតជាត្រឹមត្រូវនោះលោកអ្នកនៅ តែមានសិទ្ធិទទួលបាន IEE ដដែល ប៉ុន្តែមិនអាចប្រើប្រាស់ចំណាយសាធារណ:បានឡើយ ។

ប្រសិនបើអ្នកទទួលបានការស្ទង់ប្រមានដោយប្រើប្រាស់ចំណាយឯកជន ហើយផ្តល់លិទ្ធផលនេះទៅឲ្យ LEA លទ្ធផលនៃការស្ទង់ប្រមាណនេះនឹងត្រូវបានពិចារណាដោយក្រុម IEP ដោយស្របទៅនឹងការផ្តល់ជូនរបស់ FAPE សំរាប់កូនរបស់លោកអ្នក។ ការស្ទង់ប្រមាណដោយប្រើប្រាស់ចំណាយឯកជនអាចនឹងត្រូវបានប្រើប្រាស់ក្នុងរឿងក្តីស្តីអំពីកូនរបស់លោកអ្នក ។

ប្រសិនបើ LEA បានសង្កេតកូនលោកអ្នកដើម្បីធ្វើការស្ទង់ប្រមាណរបស់ខ្លួន ឬក្នុងករណីដែលនីតិវិធីវាយតំលៃរបស់ LEA អនុញ្ញាតិឲ្យមានការសង្កេតកូនរបស់លោកអ្នកក្នុងថ្នាក់រៀន ការធ្វើ IEE ជាឯកជនក៏ត្រូវទទួលការអនុញ្ញាតិផងដែរក្នុងការសង្កេតកូនរបស់លោកអ្នកក្នុងថ្នាក់រៀន ឬ សង្កេតបរិដ្ឋានអប់រំដែលបានស្នើរៀបចំដោយក្រុម IEP នោះ ។

បើសិនជាលោកអ្នកស្នើសុំឲ្យកូនរៀននៅសាលាឯកជនដោយចំណាយសាធារណ: LEA នឹងមានឱកាសសង្កេតមើលសាលានោះនឹងកម្មវិធីសិក្សារបស់សិស្សនៅសាលានោះ បើសិនជាសិស្សបានដាក់ឲ្យរៀនរួចទៅហើយជាឯកតោភាគីនៅសាលាឯកជនដោយមាតាបិតាឬអ្នកអាណាព្យាបាល។

## *អ្វីជាលិខិតជូនដំណឹងជាមុន ហើយតើខ្ញុំនឹងទទួលបានវានៅពេលណា?*

LEA ជាអ្នកទទួលខុសត្រូវក្នុងការជូនព័ត៌មានដល់លោកអ្នក ជាលាយលក្ខណ៏អក្សរ នៅពេលណាគេស្នើសុំឬជំទាស់ចំពោះការផ្តើមឲ្យមានការកែប្រែលើអត្តសញ្ញាញ ការស្ទង់ប្រមាណ ឬការដាក់ឲ្យកូនលោកអ្នកក្នុងកម្មវិធីសិក្សាណាមួយ។ LEA ត្រូវតែផ្តល់លិខិតជូនដំណឹងដល់លោកអ្នកដើម្បីផ្តល់ពត៌មានអំពីការស្នើសុំឬជំទាស់នេះ នៅក្នុងពេលដ៏សមរម្យមួយ ។ ក្នុងករណីដែលលិខិតជូនដំណឹងនេះមិនបានផ្តល់ដល់មាតាបិតាពីមុនទេនោះ វានឹងត្រូវបានផ្តល់ឲ្យនៅពេលដែល LEA បានទទួលសំណើរបស់មាតាបិតាអំពីការសុំធ្វើសវនាការរឿងក្តី។ លិខិតជូនដំណឹងជាលាយល័ក្ខអក្សរនេះនឹងរួមបញ្ចូលៈ

- សេចក្តីពណ៌នាអំពីវិធានការណ៍ដែលបានស្នើឡើងឬជំទាស់ដោយ LEA និងសេចក្តីពណ៌នាអំពីវិធានការណ៍ដ៏ទៃទៀតដែលបានពិចារណា និងច្រានចោលជាទូទៅ ជាមួយការពន្យល់អំពីមូលហេតុផ្សេងៗ ។
- សេចក្តីពណ៌នាអំពីដំណើរការស្ទង់ប្រមាណនិមួយៗ តែស បណ្ណសារ ឬរបាយការណ៍ផ្សេងៗដែល LEA ប្រើប្រាស់ជាមូលដ្ឋានក្នុងការស្នើឬជំទាស់ ។
- សេចក្តីពណ៌នាអំពីជំរើសផ្សេងៗទៀតដែលពិចារណានិងច្រានចោលដោយក្រុម IEP ជាមួយការពន្យល់ពីមូលហេតុ ។
- សេចក្តីពណ៌នាអំពីរាល់កត្តាផ្សេងៗទៀត ដែលជាប់ទាក់ទងនឹងការស្នើសុំ ឬជំទាស់របស់ LEA ។
- កំណត់សារដែលមាតាបិតាអាចទទួលបានច្បាប់ចំលងឬជំនួយសំរាប់ឲ្យពួកគាត់ងាយក្នុងការស្វែងយល់អំពីសិទ្ធិរបស់គាត់និងនីតិវិធីបង្ការ ពីនាយកផ្នែកអប់រំពិសេស ឬពី CDE នៅទីក្រុង Sacramento ។

## *តើអ្វីទៅជាការយល់ព្រមរបស់មាតាបិតានិងនៅពេលណាដែលវាត្រូវការ?*

LEA ត្រូវបានទទួលការយល់ព្រមពីមាតាបិតា ដូចបានចែងខាងលើ មុននឹងធ្វើការស្ទង់ប្រមាណ ឬផ្តល់សេវាកម្មអប់រំពិសេសឬសេវាកម្មផ្សេងៗដល់កូនលោកអ្នក។ LEA ត្រូវព្យាយាមគ្រប់វិធីក្នុងការទទួលការយល់ព្រមពីមាតាបិតាមុននឹងធ្វើការស្ទង់ប្រមាណកូនលោកអ្នកជាលើកទីដំបូងឬការស្ទង់ប្រមាណឡើងវិញសារជាថ្មី។ បើសិនជាលោកអ្នកបដិសេដមិនផ្តល់ការយល់ព្រមទៅលើការស្ទង់ប្រមាណឬការស្ទង់ប្រមាណសារជាថ្មីទេ LEA អាច ប៉ុន្តែមិនមានតំរូវមកទេ ប្រើទម្រង់ការរឿងក្តីដើម្បីទទួលការយល់ព្រមពីលោកអ្នកដើម្បីធ្វើការស្ទង់ប្រមាណ។ បើសិនជាលោកអ្នកបដិសេដមិនផ្តល់ការយល់ព្រមទៅលើការដាក់កូនឲ្យរៀនក្នុងកម្មវិធីអប់រំផ្ទាល់ខ្លួននិងសេវាកម្មជា *លើកទីដំបូង* LEA អាចមិនប្រើទម្រង់ការរឿងក្តីដែលមានពណ៌នាខាងក្រោម ដើម្បីតវ៉ាទៅដល់ការបដិសេដមិនយល់ព្រមរបស់លោកអ្នកទេ ។ ក៏ប៉ុន្តែ នៅពេលណា LEA ស្នើសុំការយល់ព្រមដើម្បីដាក់កូនលោកអ្នកក្នុងកម្មវិធីអប់រំផ្ទាល់ខ្លួននិងសេវាកម្មជាលើកទីដំបូងហើយលោកអ្នកពុំផ្តល់ការយល់ព្រមនេះទេ LEA នឹងមិនត្រូវចាត់ទុកថាបានបំពានលើតម្រូវការផ្សេងៗដើម្បីផ្តល់FAPE ដល់កូនលោកអ្នកទេ។ LEA ក៏នឹងមិនចាំបាច់បើកការប្រជុំ IEP ឬបង្កើតផែនការអប់រំផ្ទាល់ខ្លួនដែរ បើសិនជាការយល់ព្រមពុំមានផ្តល់ឲ្យនៅពេល LEA បានស្នើសុំ។

លោកអ្នកអាចធ្វើការយល់ព្រមជាលាយលក្ខណ៏អក្សរទៅលើការបានទទួលនូវសមាសភាគខ្លះនៃផែនការអប់រំផ្ទាល់ខ្លួនរបស់កូនលោកអ្នក ហើយនិងសមាសភាគនៃផែនការអប់រំផ្ទាល់ខ្លួនដែលត្រូវដាក់ប្រតិបត្តដោយ LEA ។ ប្រសិនបើ LEA យល់ឃើញថាសមាសភាគនៃផែនការអប់រំផ្ទាល់ខ្លួនរបស់កូនលោកអ្នកដែលនៅសល់ទាំងប៉ុន្មានដែលលោកអ្នកមិនបានផ្តល់ការយល់ព្រម គឺចាំបាច់ក្នុងការផ្តល់ឲ្យកូនលោកអ្នកនូវ FAPE LEA ត្រូវតែផ្តើមសវនាការរឿងក្តីមួយ។

ទីបញ្ចប់ ការយល់ព្រមរបស់លោកអ្នកមិនចាំបាច់មានទេនៅក្នុងករណីដែលត្រូវធ្វើការស្ទង់ប្រមាណកូនលោកអ្នកឡើងវិញ បើ LEA អាចបង្ហាញនៅក្នុងសវនាការរឿងក្តីថាគេបានខិតខំគ្រប់វិធីក្នុងការទទួលការយល់ព្រមពីលោកអ្នកហើយលោកអ្នកមិនបានឆ្លើយតប។

## *តើថ្ងៃក្រោយខ្ញុំអាចប្តូរគំនិតហើយដកហូតការយល់ព្រមរបស់ខ្ញុំវិញបានទេ*

បើសិនជានៅពេលណាមួយបន្ទាប់ពីបានផ្តល់ការអប់រំពិសេសនិងសេវកម្មផ្សេងៗ មាតាបិតាសិស្សដកហូតការយល់ព្រមជាលាយលក្ខណ៏អក្សរទៅលើការបន្តនូវកម្មវិធីនិងសេវាកម្មអប់រំពិសេស ក្រសួងអប់រំឬសាលាសាខា

- មិនត្រូវបន្តផ្តល់ការអប់រំនិងសេវាកម្មពិសេសដល់សិស្សទេ ប៉ុន្តែត្រូវផ្តល់ដំណឹងជាមុនមុននឹងបញ្ឈប់ការអប់រំនិងសេវាកម្មពិសេសនេះ
- មិនអាចប្រើទម្រង់ការនាំសម្របសម្រួលគ្នា ទម្រង់ការរឿងក្តី ដើម្បីទទួលការព្រមព្រៀងឬការកាត់សេចក្តីថាសេវាកម្មនោះត្រូវតែផ្តល់ឲ្យសិស្ស

- នឹងមិនចាត់ទុកថាបានបំពានលើតំរូវការក្នុងការផ្តល់ FAPE ដល់កូនលោកអ្នកឡើយ ដោយសារតែពុំបានផ្តល់ឲ្យកូនលោកអ្នកនូវការអប់រំនិងសេវាកម្មពិសេសតទៅទៀត ហើយ
- មិនចាំបាច់បើកការប្រជុំ IEP ឬបង្កើតផែនការអប់រំផ្ទាល់ខ្លួនសម្រាប់សិស្សទេដើម្បីបន្តការអប់រំនិងសេវាកម្មពិសេសតទៅទៀត

បើមាតាបិតាដកហូតការយល់ព្រមជាលាយលក្ខណ៏អក្សរសម្រាប់ឲ្យកូនគាត់ទទួលនូវការអប់រំនិងសេវាកម្មពិសេស ក្រោយពីសិស្សត្រូវបានផ្តល់ការអប់រំនិងសេវាកម្មពិសេសជាលើកដំបូង ក្រសួងអប់រំឬសាលាសាខាមិនតម្រូវឲ្យមានការកែទៅលើបណ្ណសារសិក្សារបស់សិស្សទេ ដើម្បីលប់ចេញនូវព័ត៏មានផ្សេងៗទាក់ទងទៅនឹងការទទួលការអប់រំនិងសេវាកម្មពិសេសរបស់សិស្សដោយសារតែការដកហូតវិញនូវការយល់ព្រម។ បដិញ្ញានេះនឹងប្រតិបត្តឡើងនៅពេលមាតាបិតាបដិសេដគ្រប់សេវាកម្មអប់រំពិសេសទាំងអស់។ បើសិនជាមាតាបិតាមិនព្រមព្រៀងទៅលើសេវាកម្មខ្លះៗហើយមិនទាំងស្រុង រឿងរ៉ាវនេះត្រូវតែដោះស្រាយតាមសវនាការរឿងក្តី។

### *បើខ្ញុំចង់ដាក់ពាក្យបណ្តឹងតវ៉ាអំពីកម្មវិធីសិក្សារបស់កូនខ្ញុំ តើខ្ញុំត្រូវធ្វើយ៉ាងដូចម្តេច?*

លោកអ្នកមានសិទ្ធិក្នុងការដាក់ពាក្យតវ៉ានិងដោះស្រាយការមិនពេញចិត្តណាមួយស្តីអំពីកម្មវិធីសិក្សារបស់កូនលោកអ្នក។ បើលោកអ្នកមានការបារម្ភណ៏អ្វីមួយដែលទាក់ទងនឹងការសិក្សារបស់កូនលោកអ្នក SELPA លើកទឹកចិត្តឲ្យលោកអ្នកយកការបារម្ភណ៏នោះទៅពីគ្រោះជាមួយគ្រូបង្រៀនរបស់កូន អ្នកអភិបាលសាលា ឬក្រុម IEP របស់កូនលោកអ្នក។

គូភាគីទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យរកដំណោះស្រាយទៅលើជំទាស់ដែលទាក់ទងនឹងកម្មវិធីអប់រំពិសេសដោយសន្តិវិធី តាមរយៈវិធីដោះស្រាយជំទាស់ដោយសម្របសម្រួលគ្នា ADR មុននឹងរកវិធីដោយស្រាយតាមរយៈរឿងក្តី។ ដំណោះស្រាយនៅក្នុង ADR នឹងប្រព្រឹត្តធ្វើទៅដោយបរិយាកាសសន្តិវិធីដើម្បីដោះស្រាយរឿងរ៉ាវផ្សេងៗដែលទាក់ទៅនឹងអត្តសញ្ញាណកម្ម ការស្ទង់ប្រមាណ ឬការចាត់ដាក់កម្មវិធីសិក្សាឲ្យសិស្ស ហើយនិងការផ្តល់ FAPE ដល់សិស្ស ដែលពេញចិត្តដល់គូភាគីទាំងសងខាង។ ហេតុដូច្នោះ មេធាវីឬអ្នកជំនាញច្បាប់ណាដែលបានប្រើប្រាសក្នុងការផ្តល់នូវយោបល់ណែនាំផ្លូវច្បាប់មិនចាំបាច់មកចូលរួមនៅក្នុងការរកដំណោះស្រាយនេះទេ។ ការនេះក៏មិនរារាំងភាគីណាមួយពីការពីគ្រោះជាមួយមេធាវីដែរទោះបីនៅមុនពេលឬក្រោយពេល ADR ក្តី ឬមួយក៏មិនរារាំងមាតាបិតាសិស្សពីការចូលរួមនៅក្នុងដំណោះស្រាយនេះឡើយដោយសារតែគាត់ជាមេធាវីនោះ។

ប្រសិនបើ LEA មិនអាចដោះស្រាយការបារម្ភណ៏របស់លោកអ្នកតាមវិធីក្រៅឲ្យផ្លូវការនេះ លោកអ្នកអាចដាក់ពាក្យតវ៉ាជាមួយLEA ឬក្រសួងអប់រំប្រចាំរដ្ឋកាលីហ្វ័រនីញ៉ា CDE ។

បើសិនជាការជំទាស់របស់លោកអ្នកទាក់ទងទៅនឹងសំណើរឬការបដិសេដក្នុងការចាប់ផ្តើមឬកែប្តូរអត្តសញ្ញាណកម្ម ការស្ទង់ប្រមាណ ឬការចាត់ដាក់កម្មវិធីសិក្សាឲ្យសិស្សដែលមានពិការភាព ការផ្តល់ FAPE ដល់សិស្ស ឬជំទាស់ទៅលើកង្វះនៃកម្មវិធីសិក្សាសមរម្យមួយសម្រាប់កូនលោកអ្នក លោកអ្នកអាចដាក់ពាក្យធ្វើសវនាការរឿងក្តីមួយ(ពណ៌នាខាងក្រោម)។ LEA ក៏មានសិទ្ធិដែរក្នុងការដាក់ពាក្យធ្វើសវនាការរឿងក្តីទៅលើរឿងរ៉ាវអ្វីមួយដែល ទាក់ទងទៅនឹងសំណើរឬការបដិសេដក្នុងការចាប់ផ្តើមឬកែប្តូរ អត្តសញ្ញាណកម្ម ការស្ទង់ប្រមាណ ឬការចាត់ដាក់កម្មវិធីសិក្សាឲ្យសិស្សដែលមានពិការភាព ការផ្តល់ FAPE ដល់សិស្ស ឬជំទាស់ទៅលើការមាននូវកម្មវិធីសិក្សាសមរម្យមួយសម្រាប់កូនលោកអ្នកជាដើម។

### *តើអ្វីទៅជាការតវ៉ាស្តីអំពីការអនុវត្តឲ្យស្របតាមច្បាប់ហើយតើខ្ញុំមានសិទ្ធិអ្វីខ្លះទៅលើការតវ៉ាស្តីអំពីការអនុវត្តឲ្យស្របតាមច្បាប់*

គ្រប់ពាក្យបណ្តឹងស្តីពីការអនុវត្តឲ្យស្របតាមច្បាប់ទាំងអស់ដែលចោទថាបានរំលោភទៅលើច្បាប់ IDEA ឬច្បាប់ស្តីពីការអប់រំពិសេសរបស់រដ្ឋកាលីហ្វ័រនីញ៉ាត្រូវមានលក្ខខ័ណ្ឌដូចតទៅៈ (១)ធ្វើឡើងជាលាយល័ក្ខអក្សរ (២)មានភ្ជាប់ជាមួយការបរិយាយអំពីការបំពានរបស់ LEA ទៅលើច្បាប់លក្ខន្តិកៈណាមួយរបស់ IDEA ឬរបស់ច្បាប់ស្តីពីការអប់រំពិសេសរបស់រដ្ឋកាលីហ្វ័នីញ៉ា (៣)រួមបញ្ចូលហេតុការណ៏ពិតទាំងឡាយដែលគាំទ្រដល់ការចោទប្រកាន់ (៤)មានចុះហត្ថលេខានិងពត៏មានទំនាក់ទំនងរបស់អ្នកធ្វើបណ្តឹង និង (៥)បើចោទពីការបំពានលើក្មេងតែមួយរូបណានោះ ត្រូវមានៈ (ក)ឈ្មោះនិងអាស័យដ្ឋានរបស់ក្មេង (ឬពត៏មានទំនាក់ទំនងរបស់ក្មេងបើសិនរូបគេគ្មានទីលំនៅ) (ខ)ឈ្មោះនិងអាស័យដ្ឋានរបស់សាលាដែលក្មេងទៅរៀន (គ)សេចក្តីពណ៌នាអំពីលក្ខណៈនិងការពិតដែលទាក់ទងនឹងបញ្ហា និង (ឃ)រាល់ដំណោះស្រាយទាំងឡាយដែលបានលើកដាក់ចំពោះមុខទាំងអស់ដែលអ្នកបានដឹង។

***<u>ពាក្យបណ្តឹងស្តីពីការអនុវត្តឲ្យស្របតាមច្បាប់នៅដំណាក់ក្រសួងអប់រំៈ</u>*** SELPA បានលើកទឹកចិត្តលោកអ្នកឲ្យដាក់ពាក្យបណ្តឹងអ្វីមួយស្តីពីការអប់រំពិសេសផ្ទាល់តែម្តងជាមួយ LEA ដើម្បីឲ្យ LEA រិះរកដំណោះស្រាយទៅលើការបារម្ភណ៏របស់លោកអ្នកឲ្យបានឆាប់ៗតាម

បែបបទក្រៅផ្លូវការនិងតាមវិធីដែលមានប្រសិទ្ធិភាពមួយ។ LEA បានបង្កើតនូវនីតិវិធីរក្សាភាពសម្ងាត់មួយសំរាប់ទទួលពាក្យបណ្តឹងទាំងនោះហើយនឹងជួបជាមួយលោកអ្នកដើម្បីអង្កេតអំពីពាក្យបណ្តឹងរបស់អ្នកឲ្យបានទាន់ពេលវេលា ដើម្បីព្យាយាមដោះស្រាយរាល់បញ្ហាទាំងអស់។ មន្ត្រីមុខការនឹងជួយលោកអ្នកក្នុងការដោះស្រាយរាល់ពាក្យបណ្តឹងស្តីពីការរើសប្រកាន់ ជាមួយក្រសួងអប់រំ បុគ្គលិកក្រសួងអប់រំ អ្នកមានកុងត្រាជាមួយក្រសួងអប់រំ និងសិស្ស។ ម៉្យាងទៀត មន្ត្រីមុខការក៏អាចជួយលោកអ្នកក្នុងការរៀបចំពាក្យបណ្តឹងជាលាយល័ក្ខអក្សរដោយភ្ជាប់ជាមួយពត៌មានទាំងឡាយតំរូវដោយច្បាប់។ នៅពេលដែលសមស្រប មន្ត្រីមុខការនឹងណែនាំឲ្យអ្នកទៅសុំជំនួយពីទីភ្នាក់ងារដទៃៗទៀតដែលមានភារកិច្ចអង្កេតនិងដោះស្រាយពាក្យបណ្តឹង ។

***<u>ពាក្យបណ្តឹងស្តីពីការអនុវត្តឲ្យស្របតាមច្បាប់នៅដំណាក់រដ្ឋ:</u>*** បុគ្គលណាម្នាក់ឬអង្គការណាមួយអាចដាក់ពាក្តបណ្តឹងពីការអនុវត្តស្របតាមច្បាប់ដែលចោទពីការបំពានលើច្បាប់ IDEA ឬច្បាប់របស់រដ្ឋដែលតម្រូវមកដោយ LEA, CDE ឬអង្គការឯកជនណាមួយទៀត។ មន្ត្រីមុខការក៏អាចជួយអ្នកក្នុងការរៀបចំពាក្យបណ្តឹងជាលាយល័ក្ខអក្សរ ដោយភ្ជាប់ជាមួយពត៌មានទាំងឡាយដែលតំរូវដោយច្បាប់។ នៅពេលដែលសមស្រប មន្ត្រីមុខការនឹងណែនាំឲ្យអ្នកទៅសុំជំនួយពីទីភ្នាក់ងារដទៃៗទៀតដែលមានភារកិច្ចអង្កេតនិងដោះស្រាយពាក្យបណ្តឹង។ **ពាក្យបណ្តឹងទាំងអស់គួរត្រូវបានបញ្ជូនទៅមន្ទីរអប់រំរបស់រដ្ឋកាលីហ្វ័រនីញ៉ាផ្នែកការអនុវត្តឲ្យស្របតាមច្បាប់ អាស័យដ្ឋាន California Department of Education, Special Education Division, Procedural Safeguards Referral Service, 1430 N. Street, Suite 2401, Sacramento, Ca 95814, ទូរស័ព្ទ (800) 926-0648 ហ្វាក់ស (916) 327-3704.**

ពាក្យបណ្តឹងផ្ញើទៅ CDE ត្រូវធ្វើឡើងឲ្យបានក្នុងកំឡុងពេល ១ឆ្នាំបន្ទាប់ពីពេល ដែលអ្នកបានដឹងឬមានទទួលបានហេតុការណ៍ពិតទាំងឡាយដែលជាមូលដ្ឋានសំរាប់ពាក្យបណ្តឹង ។

ក្នុងកំឡុងពេល៦០ថ្ងៃបន្ទាប់ពីលោកអ្នកបានដាក់ពាក្យបណ្តឹង CDE នឹង (១)ធ្វើការស៊ើបអង្កេតដោយផ្ទាល់នៅសាលារៀន បើចាំបាច់ (២)ផ្តល់ឱកាសឲ្យលោកអ្នកដាក់ប្រគល់ពត៌មានថែមទៀត ទោះបីដោយមាត់ឬដោយលាយល័ក្ខអក្សរស្តីពីការចោទទាំងឡាយនៅក្នុងពាក្យបណ្តឹង (៣)ផ្តល់ឱកាសឲ្យLEA ដើម្បីធ្វើការឆ្លើយតបទៅនឹងពាក្យបណ្តឹង រួមទាំងសំណើរសុំដោះស្រាយជំទាស់ (៤)ផ្តល់ឱកាសឲ្យលោកអ្នកនឹងLEA ឲ្យព្រមព្រៀងស្ម័គ្រចិត្តរកអ្នកនាំដំណោះស្រាយ (៥)ពិនិត្យមើលព័ត៌មានទាក់ទងទាំងអស់ហើយនឹងធ្វើការសំរេចថាតើ LEA បានបំពានលើច្បាប់ដែលតម្រូវមកដោយ IDEA ឬច្បាប់របស់រដ្ឋ និង(៦)ផ្តល់ការសម្រេចចិត្តជាលាយល័ក្ខទៅឲ្យលោកអ្នកនិង LEA ស្តីអំពីការចោទនិមួយៗនៅក្នុងពាក្យបណ្តឹងនឹងាការរកឃើញនូវហេតុការណ៏ពិតទាំងឡាយ ព្រមទាំងការសម្រេចផ្តាច់ព្រ័តហើយនិងមូលហេតុនៃការសម្រេចផ្តាច់ព្រ័តនេះផងដែរ។

## *អ្វីជាការនាំសំរបសំរួល ហើយខ្ញុំអាចស្នើសុំវាបាននៅពេលណា ?*

ភាគីទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យស្វែងរកដំណោះស្រាយជំទាស់ពីការអប់រំពិសេស តាមរយៈដំណើរការដោយសន្តិវិធី ដូចជាការសំរបសំរួលនិងដំណោះស្រាយជំទាស់តាមផ្លូវផ្សេង (ADR) មុននឹងដាក់ពាក្យសុំឲ្យធ្វើសវនាការរឿងក្តី។ នៅពេលដែលលោកអ្នកត្រូវបានលើកទឹកចិត្តឲ្យសាកល្បង ADR នេះ គឺមិនមែនដើម្បីសម្រាប់ពន្យាដល់សិទ្ធិរបស់លោកអ្នកក្នុងការសុំឲ្យធ្វើសវនាការរឿងក្តីនោះទេ។ សន្និសិទដើម្បីសំរបសំរួលមុនសវនាការទាំងនេះគឺត្រូវបានធ្វើឡើងក្នុងបរិយាកាសសន្តិវិធីមួយ ដើម្បីដោះស្រាយរបញ្ហាទាក់ទងនឹង អត្តសញ្ញាណកម្មការស្ទង់ប្រមាណ ឬការចាត់ដាក់កម្មវិធីសិក្សាដល់ក្មេង ឬទាក់ទងការផ្តល់ជូនរបស់ FAPE ដល់កូនរបស់លោកអ្នក ដោយមានការសុខចិត្តពីភាគីទាំងសង្ខាង។ ដូច្នេះហើយទើបមេធាវីឬអ្នកផ្តល់សេវាកម្ម ដែលផ្តល់សេវាកម្មជំនួយផ្នែកច្បាប់ទាំងអស់មិនត្រូវចូលរួមក្នុងសន្និសិទដើម្បីសំរបសំរួលមុនសវនាការដែលបានស្នើសុំនេះឡើយ។ ការណ៍នេះមិនហាមឃាត់ភាគីនិមួយៗពីការសុំ យោបល់ពីមេធាវីរបស់ខ្លួនមុនឬក្រោយដំណើរការសំរបសំរួលនេះទេ ហើយក៏មិនរារាំងមាតាបិតារបស់ក្មេងដែលជាមេធាវីស្រាប់នោះពីការចូលរួមឡើយ។ ភាគីនិមួយៗអាចនឹងទទួលយោបល់និងអមដោយបណ្តាអ្នកតំណាងដែលមិនមានវិជ្ជាជីវៈជាមេធាវីទៅតាមការសំរេចរបស់ខ្លួន។

សន្និសិទសំរបសំរួលនេះនឹងត្រូវបានរៀបចំធ្វើឡើងក្នុងរយៈពេល១៥ថ្ងៃ ហើយបញ្ចប់រួចរាល់ក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពី CDE បានទទួលសំណើពីលោកអ្នកដែលសុំឲ្យមានការសំរបសំរួល លើកលែងតែភាគីទាំងសង្ខាងព្រមព្រៀងពន្យារពេល។ ការសំរបសំរួលនេះនឹងត្រូវដឹកនាំដោយអ្នកនាំសំរបសំរួលដែលមិនលំអៀងម្នាក់ហើយដែលបានទទួលការហ្វឹកហ្វឺនក្នុងការប្រើវិធីសំរបសំរួលឲ្យមានប្រសិទ្ធិភាព។

បើលោកអ្នកនិងLEA បានដោះស្រាយជំទាស់តាមរយៈការសំរបសំរួលនេះ ភាគីទាំងសង្ខាងត្រូវចុះការព្រមព្រៀងបញ្ជាក់តាមច្បាប់មួយថាការព្រមព្រៀងនេះគឺ: (១)បញ្ជាក់ថាការពិភាក្សាទាំងអស់ដែលបានកើតឡើងនៅក្នុងដំណើរការនៃការសំរបសំរួលនឹងត្រូវរក្សាទុកដោយ

សម្គាត់ហើយនឹងមិនត្រូវយកទៅប្រើប្រាសនៅពេលធ្វើសវនាការរឿងក្ដីនៅថ្ងៃក្រោយទេ ហើយ (២)បានចុះហត្ថលេខាដោយគូភាគីទាំងពីរ និងអ្នកតំណាងម្នាក់របស់ LEA ដែលមានអំណាចទៅលើការបញ្ជាក់តាមច្បាប់នេះ។

ការព្រមព្រៀងដោយសំរបសំរួលគ្នាជាលាយល័ក្ខអក្សរដែលបានចុះហត្ថលេខាគឺជាភស្តុតាងនៅក្នុងតុលាការណាមួយក្នុងរដ្ឋដែលមានយុត្តាធិការ(តុលាការដែលមានអំណាចនៅក្រោមច្បាប់រដ្ឋក្នុងការធ្វើសវនាការទៅលើរឿងរ៉ាវបៀបនេះ) ឬនៅក្នុងតុលាប្រចាំតំបន់នៅក្នុងសហរដ្ឋអាមេរិក។ ការពិភាក្សាទាំងអស់ដែលបានកើតឡើងនៅក្នុងដំណើរការនៃការសំរបសំរួលត្រូវតែរក្សាទុកដោយសម្ងាត់។ ការពិភាក្សានោះមិនត្រូវយកទៅប្រើប្រាសជាភស្តុតាងនៅក្នុងការសវនាការរឿងក្ដីអ្វីមួយនៅថ្ងៃមុខនៅក្នុងតុលាការរដ្ឋឬសហព័ន្ធបានឡើយ។

## *អ្វីទៅជាសវនាការរឿងក្ដី ហើយតើខ្ញុំមានសិទ្ធិអ្វីខ្លះទាក់ទងនឹងសវនាការនេះ ?*

សវនាការរឿងក្ដីគឺជាការដោះស្រាយតាមផ្លូវច្បាប់ជាផ្លូវការមួយ ដែលស្ថិតក្រោមអធិបតេយ្យភាពរបស់ចៅក្រមផ្នែកច្បាប់រដ្ឋបាលប្រហាក់ប្រហែលទៅនឹងតុលាការស៊ីវិលដែរ។ សវនាការអាចនឹងត្រូវបានចាប់ផ្ដើមដោយមាតាបិតាឬដោយLEA នៅពេលដែលមានការមិនយល់ស្របគ្នាទៅលើ ការស្នើសុំឬការបដិសេធ ចំពោះការចាប់ផ្ដើមឬការកែប្រែអត្តសញ្ញាណកម្ម ការស្ទង់ប្រមាណ ការចាត់ដាក់កម្មវិធីសិក្សាសំរាប់កូនលោកអ្នក ឬនៅពេលមានភាពមិនចុះសម្រុងគ្នាទៅលើការផ្ដល់ជូននូវ FAPE ដល់កូនលោកអ្នក ឬការជំទាស់គ្នាស្ដីពីការមានកម្មវិធីអប់រំសមរម្យមួយសម្រាប់កូនលោកអ្នក។ រាល់សំណើទាំងអស់នឹងត្រូវបញ្ជូនទៅ **ការិយាល័យសវនាការរដ្ឋបាល Office of Administrative Hearings (OAH), នៅអាស័យដ្ឋាន Office of Administrative Hearings, Attn: Special Education Division, 2349 Gateway Oaks Drive, Suite 200, Sacramento, CA 95833-4231 ទូរស័ព្ទ (916) 263-0880 ហ្វាក់ស (916) 263-0890 ។**

សំណើសុំឲ្យមានសវនាការរឿងក្ដី ត្រូវធ្វើឡើងឲ្យបានក្នុងកំឡុងពេល២ឆ្នាំ បន្ទាប់ពីពេលដែលអ្នកបានដឹង ឬមានទទួលបានហេតុការណ៍ពិតទាំងឡាយ ដែលជាមូលដ្ឋានសំរាប់សំណើសុំសវនាការ។ ការកំរិតកំឡុងពេលនេះពុំមានទាក់ទងនឹងលោកអ្នកទេបើសិនជាលោកអ្នកត្រូវបានរារាំងពីការស្នើសុំឲ្យបានទាន់ពេល ដោយសារ LEA (១)យល់ច្រលំថា ខ្លួនបានដោះស្រាយបញ្ហាដែលអ្នកបានលើកឡើងក្នុងសំណើរួចរាល់ហើយ ឬ(២)បិទបាំងពត៌មានដែលមានក្នុងឯកសារនេះមិនឲ្យអ្នកដឹង។

សំណើសុំសវនាការរបស់លោកអ្នក**ត្រូវ**តែមាននូវព័ត៌មានបន្ទាប់ទៅនេះ: (១)ឈ្មោះរបស់កូនលោកអ្នក (២)អាស័យដ្ឋានរបស់កូនលោកអ្នក (ឬពត៌មានទំនាក់ទំនងរបស់ក្មេង បើសិនរូបគេគ្មានទីលំនៅ) (៣)ឈ្មោះនិងអាស័យដ្ឋានរបស់សាលាដែលក្មេងទៅរៀន (៤)សេចក្ដីពណ៌នាអំពីបញ្ហាទាក់ទងការកែប្រែឬផ្ដួចផ្ដើម ដែលបានស្នើឡើងនោះដោយរួមបញ្ចូលហេតុការណ៍ពិតជាក់លាក់ទាំងឡាយរបស់បញ្ហា និង (៥)ការព្យាយាមរកដំណោះស្រាយដែលបានស្នើឡើងទាំងអស់ ដែលលោកអ្នកអាចដឹងឮទាំងអស់។ លោកអ្នកត្រូវផ្ដល់ឲ្យ LEA មួយចម្លងនូវពាក្យសុំរឿងក្ដីនេះ។ លោកអ្នក (ឬ LEA) នឹងមិនអាចចាប់ផ្ដើមសវនាការរឿងក្ដីបានទេលុះណាទាល់ការបណ្ដឹងឲ្យមានសវនាការរឿងក្ដីនោះមានព័ត៌មានដែលរាយមកខាងលើនេះសព្វគ្រប់ទាំងអស់ហើយបានដាក់ប្រគល់ឲ្យ។

បើលោកអ្នកស្នើសុំឲ្យមានសវនាការរឿងក្ដី ក្នុងរយៈពេល១៥ថ្ងៃនៃការទទួលបានការស្នើសុំសវនាការរឿងក្ដីរបស់លោកអ្នកនោះ LEA ត្រូវតែបើកការប្រជុំមួយជាមួយលោកអ្នក សមាជិកក្រុម IEP របស់កូនលោកអ្នកដែលពាក់ព័ន្ធនិងមានការដឹងឮអំពីហេតុការណ៍ពិតដូចមានកត់សម្គាល់នៅក្នុងសវនាការរឿងក្ដី និងអ្នកតំណាង LEA ដែលមានសិទ្ធិខាងសំរេចចិត្ត ដើម្បីឲ្យមកប្រជុំពិភាក្សារកដំណោះស្រាយចំពោះបញ្ហាដែលបានលើកឡើង។ ការប្រជុំនេះនឹងពុំមានការចូលរួមដោយមេធាវីរបស់ LEA ទេលើកលែងតែលោកអ្នកមានមេធាវីរបស់លោកអ្នកមកជាមួយដែរ។

លើកលែងតែពេលណាដែលលោកអ្នកនិង LEA បានព្រមព្រៀងជាលាយល័ក្ខអក្សរថាមិនបាច់ប្រើដំណើរការដោះស្រាយជំទាស់ឬការសំរបសំរួលគ្នា ការដែលលោកអ្នកមិនបានមកចូលរួមនៅក្នុងដំណើរការដោះស្រាយជំទាស់នេះនឹងពន្យារពេលដល់ថ្ងៃធ្វើការដោះស្រាយជំទាស់និងសវនាការរឿងក្ដីរហូតដល់ពេលដែលលោកអ្នកសុខចិត្តមកចូលរួមនៅក្នុងការប្រជុំមួយ។

ប្រសិនបើមានការព្រមព្រៀងគ្នានៅក្នុងពេលដោះស្រាយជំទាស់ ការព្រមព្រៀងនេះត្រូវកត់ត្រាជាលាយល័ក្ខអក្សរនិងចុះហត្ថលេខាដោយលោកអ្នកនិងអ្នកតំណាង LEA ។ បន្ទាប់ពីការចុះហត្ថលេខា លោកអ្នកនិង LEA មានរយៈពេល៣ថ្ងៃបើចង់លប់ចោលនូវកិច្ចព្រមព្រៀងនោះវិញ។ បើសិនជា LEA មិនបានរកដំណោះស្រាយទៅលើការបណ្ដឹងរឿងក្ដីដែលមានការពេញចិត្តពីលោកអ្នកបានទេនៅក្នុងកំឡុងរយៈពេល៣០ថ្ងៃបន្ទាប់ពីបានទទួលពាក្យបណ្ដឹងរឿងក្ដី(ក្នុងកំឡុងរយៈពេលសម្រាប់ដំណើរការដោះស្រាយ) សវនាការ

រឿងក្តីអាចចាប់ផ្តើមឡើង ហើយនិងកំឡុងពេលវេលានៃការធ្វើការសម្រេចចិត្តជាផ្តាច់ព្រ័តក៏នឹងចាប់ផ្តើមឡើងដែរ។

លោកអ្នកហើយនិង LEA អាចយល់ព្រម នៅពេលណាក៏បានឲ្យតែមុនពេលសវនាការរឿងក្តីចាប់ផ្តើម ចូលរួមក្នុងការសំរបសំរួលជំទាស់អ្វីមួយ។ អ្នកដឹកនាំសំរបសំរួលដោយមិនលំអៀងម្នាក់នឹងត្រូវតែងតាំងឡើងដោយ OAH ដោយឥតគិតថ្លៃដល់ភាគីណាមួយឡើយ។ ការសំរបសំរួលអ្វីមួយនឹងបន្តពេលវេលាដល់ OAH ក្នុងការធ្វើការសម្រេចចិត្ត ក៏ប៉ុន្តែការសំរបសំរួលនេះមិនមែនសម្រាប់បដិសេធឬពន្យារពេលដល់សិទ្ធិរបស់លោកអ្នកក្នុងការធ្វើសវនាការ ឬសិទ្ធិអ្វីៗផ្សេងៗទៀតឡើយ។

ប្រសិនបើបញ្ហាដែលបានលើកឡើងក្នុងបណ្តឹងមិនត្រូវបានដោះស្រាយក្នុងដំណើរស្វែងរកដំណោះស្រាយ ដំណើរការសំរបសំរួល ឬ ADR នោះ OAH ត្រូវតែបើកសវនាការ រួចផ្តល់ការសំរេចចុងក្រោយ ដោយផ្ញើឯកសារចំឡងមួយស្តីពីការសំរេចនេះទៅភាគីទាំងពីរ ក្នុងរយៈពេល៤៥ថ្ងៃបន្ទាប់ពីការផុតកំណត់នៃរយៈពេលស្វែងរកដំណោះស្រាយនេះ។ សវនាការត្រូវតែធ្វើឡើងនៅទីតាំងនិងពេលវេលាដែលមានភាពងាយស្រួលសំរាប់ភាគីទាំងអស់។

ភាគីណាមួយដែលចូលរួមក្នុងសវនាការរឿងក្តីមានសិទ្ធិនឹង (១) បានទទួលសវនការប្រកបដោយយុត្តិធម៌ នៅចំពោះមុខបុគ្គលណាណាម្នាក់ដែលមានចំណេះដឹងផ្នែកច្បាប់ទាក់ទងនឹងសវនាការផ្នែករដ្ឋបាលនិងការអប់រំពិសេស (២) មានតំណាងដោយមេធាវីឬអ្នកតំណាងណាម្នាក់ដែលមានការចេះដឹងនិងបទពិសោធន៍ទាក់ទងនឹងក្មេងឬយុវជនដែលមិនមានអសមត្ថភាព (៣) លើកបង្ហាញភស្តុតាង ការជជែកតវ៉ាជាលាយល័ក្ខអក្សរនិងជាពាក្យសំដី (៤)ប្រឈមមុខ សួរចម្លើយ និងឲ្យសាក្សីចូលរួមក្នុងសវនាការ (៥) បានទទួលជាលាយលក្ខអក្សរឬជាអេឡិកត្រូនិកទៅតាមជំរើសរបស់លោកអ្នក នូវកំណត់ត្រាដែលត្រឹមត្រូវតាមព្រឹត្តិការណ៍នៃសវនាការ (៦)បានទទួលជាលាយលក្ខអក្សរឬជាអេឡិកត្រូនិកទៅតាមជំរើសរបស់លោកអ្នក ការរកឃើញនៃការពិតផ្សេងៗនិងសេចក្តីសំរេចចុងក្រោយ ក្នុងកំឡុងរយៈពេល៤៥ថ្ងៃ បន្ទាប់ពីការផុតកំណត់នៃរយៈពេលស្វែងរកដំណោះស្រាយនេះ (៧)បានទទួលដំណឹងពីភាគីម្ខាងទៀត យ៉ាងតិចណាស់១០ថ្ងៃមុននឹងថ្ងៃសវនាការ ថាតួភាគីនោះនឹងមានមេធាវីជាតំណាង (៨)បានទទួលដំណឹងពីភាគីម្ខាងទៀត យ៉ាងតិចណាស់១០ថ្ងៃមុននឹងថ្ងៃសវនាការ អំពីរឿងក្តីរបស់គេហើយនិងសំណើរដំណោះស្រាយរបស់គេ (៩)បានទទួលឯកសារចម្លងទាំងអស់ រួមទាំងការស្ទង់ប្រមាណដែលធ្វើចប់មុនថ្ងៃនោះនិងអនុសាសន៏ផ្សេងៗ ហើយនិងបញ្ជីឈ្មោះអ្នកធ្វើសាក្សីនឹងផ្នែករឿងរ៉ាវដែលអ្នកទាំងនោះនឹងធ្វើជាសាក្សីយ៉ាងតិចណាស់៥ថ្ងៃមុនថ្ងៃសវនាការ (១០)ឲ្យកូនលោកអ្នកមកចូលរួមក្នុងសវនាការ (១១)ឲ្យសវនាការ មានលក្ខណៈបើកចំហរជាសាធារណៈឬដោយសំងាត់ (១២)មានផ្តល់អ្នកបកប្រែភាសា (១៣)ស្នើសុំពន្យារកាលកំណត់បើកសវនាការដោយមានមូលហេតុត្រឹមត្រូវ និង(១៤)សុំស្នើឲ្យក្រសួងអប់រំរបស់កូនលោកអ្នក SELPA ឬOAH ផ្តល់ឲ្យលោកអ្នកនូវបញ្ជីមួយដែលមានឈ្មោះបុគ្គលដែលផ្តល់សេវាកម្មផ្លូវច្បាប់ឬជាអ្នកតំណាងសម្រាប់សិស្សដែលមានពិការភាព។

### *ចុះប្រសិនបើខ្ញុំបដិសេធលទ្ធផលនៃសវនាការរឿងក្តី ?*

សេចក្តីសំរេចរបស់សវនាការគឺជាការសម្រេចចុងក្រោយហើយត្រូវតែអនុវត្តដោយភាគីទាំងពីរ។ ភាគីនិមួយៗអាចស្នើឲ្យមានការវិនិច្ឆ័យសាជាថ្មីទៅលើការសំរេចចិត្តនេះ ទៅតុលាការសមរម្យណាមួយ។ តាមផ្លូវរដ្ឋការស៊ីវិល កំណត់ត្រាផ្សេងៗនិងការប្រព្រឹត្តិទៅនៃនីតិវិធីរដ្ឋបាលដែលបានធ្វើហើយពីមុននោះ នឹងត្រូវបានបញ្ជូនទៅតុលាការ។ តុលាការអាចនឹងស្តាប់ការផ្តល់ភស្តុតាងបន្ថែមទៅតាមសំណើរបស់ភាគីណាមួយ រួចធ្វើការសំរេចចិត្តដោយផ្អែកទៅលើឧត្តមានុភាពនៃភស្តុតាងនោះ។ សំណើឲ្យធ្វើការវិនិច្ឆ័យសាជាថ្មីនេះត្រូវតែធ្វើឡើងក្នុងកំឡុងពេល៩០ថ្ងៃបន្ទាប់ពីថ្ងៃនៃសេចក្តីសំរេចរបស់ចៅក្រមរដ្ឋបាល។

### *តើកូនរបស់ខ្ញុំនឹងត្រូវបានដាក់ឲ្យរៀននៅទីណា ក្នុងកំឡុងពេលនៃដំណើរការសវនាការរឿងក្តីកំពុងប្រព្រឹត្តិទៅ ?*

នៅពេលណាដែល LEA បានទទួលសំណើរឿងក្តី ក្នុងកំឡុងពេលនៃដំណើរការសវនាការរឿងក្តីកំពុងប្រព្រឹត្តិទៅ ហើយនៅក្នុងពេលដែលកំពុងរង់ចាំការសម្រេចទៅលើសវនាការរឿងក្តីឬការសម្រេចរបស់តុលាការ សិស្សត្រូវតែនៅរៀននៅក្នុងកម្មវិធីសិក្សាបច្ចុប្បន្ន លើកលែងតែមាតាបិតានិង LEA ព្រមព្រៀងគ្នាទៅលើកម្មវិធីសិក្សាណាមួយរបស់សិស្ស។

បើសិនជាសំណើរឿងក្តីរបស់លោកអ្នកមានទាក់ទងនឹងការដាក់ពាក្យសុំចូលរៀននៅសាលាសាធារណៈជាលើកដំបូង កូនលោកអ្នកដោយមានការយល់ព្រមពីលោកអ្នក ត្រូវតែដាក់ឲ្យរៀនក្នុងកម្មវិធីសិក្សាជាទូទៅរហូតទាល់តែរឿងក្តីបានចប់សព្វគ្រប់។

បើសិនជាសំណើរឿងក្តីរបស់លោកអ្នកមានទាក់ទងនឹងការដាក់ពាក្យសុំសេវាកម្មជាលើកដំបូងសម្រាប់សិស្សដែលបានទទួលសេវាកម្មនៅក្នុងផែនការសេវាកម្មផ្ទាល់ខ្លួនសម្រាប់គ្រួសារ (IFSP) ហើយមានអាយុគ្រប់បីឆ្នាំ LEA មិនចាំបាច់ផ្តល់សេវាកម្ម IFSP ដែលកូនលោកអ្នកបានទទួលកន្លងមកនោះទេ។ បើសិនជាកូនលោកអ្នកត្រូវបានរកឃើញថាមានសិទ្ធិបានទទួលការអប់រំពិសេសពី LEA ហើយលោកអ្នកយល់

ព្រមឲ្យកូនបានទទួលសេវាកម្មអប់រំពិសេសជាលើកទីដំបូង ហើយនៅក្នុងពេលដែលកំពុងរង់ចាំការសម្រេចទៅលើសវនាការរឿងក្តី LEA ត្រូវតែផ្តល់សេវាកម្មនិងការអប់រំពិសេសដែលមិនមែនជាចំណែកនៅក្នុងរឿងក្តី(សេវាកម្មណាដែលលោកអ្នកនិង LEA យល់ព្រមគ្នា)។

បើកូនលោកអ្នកបានដាក់ឲ្យរៀននៅក្នុងស្ថានភាពសិក្សាពិសេសជាបណ្តោះអាសន្ន (“IAES”) ក្មេងរូបនោះនឹងរក្សាឲ្យនៅក្នុង IAES នេះសំរាប់រយៈពេលយ៉ាងយូរ៤៥ថ្ងៃដើម្បីរង់ចាំការបញ្ចប់នៃដំណើរសវនាការសេវាអប់រំឬរហូតដល់កាលផុតកំណត់នៃ IAES ដោយអាស្រ័យលើដំណើរការណាមួយដែលបានកើតឡើងមុនគេ។

### *តើស្ថិតក្នុងស្ថានភាពណា ទើបថ្លៃឈ្នួលមេធាវីរបស់ខ្ញុំត្រូវបានសងត្រលប់មកឲ្យខ្ញុំវិញ ?*

តាមសមត្ថកិច្ចរបស់ខ្លួន តុលាការអាចនឹងដាក់ឲ្យ LEA សងថ្លៃមេធាវីរបស់មាតាបិតាក្មេងមានពិការភាព ប្រសិនបើមាតាបិតាឈ្នះរឿងក្តីសវនាការរឿងក្តីនោះ។ លើសពីនេះទៅទៀត LEA អាចនឹងត្រូវទទួលសំណងថ្លៃមេធាវីតបតនឹងមេធាវីរបស់មាតាបិតាឬតបតនឹងមាតាបិតាដែលដាក់ពាក្យបណ្តឹងដែលជាលទ្ធផលបង្ហាញពីការខាតបង់ពេលវេលា គ្មានហេតុផល គ្មានមូលដ្ឋាន ឬមាតាបិតាដែលបន្តប្តឹងតវ៉ាបន្ទាប់រឿងក្តីប្រែក្លាយយ៉ាងច្បាស់ជាការខាតបង់ពេលវេលាគ្មានហេតុផល គ្មានមូលដ្ឋាន ។ LEA ក៏អាចនឹងទទួលបានផងដែរនូវថ្លៃមេធាវីតបតនឹងមេធាវីរបស់មាតាបិតា ឬតបតនឹងមាតាបិតា ក្នុងករណីពាក្យបណ្តឹងរបស់មាតាបិតាជាលទ្ធផលបង្ហាញពីគោលបំណងមិនសមរម្យដូចជាគោលបំណងរករឿងរកាំរកូស ធ្វើឲ្យមានការយឺតយ៉ាវឥតប្រយោជន៍ និងធ្វើឲ្យថ្លៃចំណាយលើការដោះស្រាយក្តីកើនឡើងដោយមិនចាំបាច់។

តុលាការអាចកាត់បន្ថយសំណងថ្លៃមេធាវី ប្រសិនបើ(១)មាតាបិតាធ្វើឲ្យមានការពន្យារដោយមិនមានហេតុផលចំពោះការដោះស្រាយរឿងក្តី (លើកលែងតែ LEA ក៏ពន្យារដូចគ្នានេះដែរ ឬបំពានល្មើសទៅនឹងនីតិវិធីសវនាការរឿងក្តី) (២)ថ្លៃចំណាយមានចំនួនលើសពីថ្លៃធម្មតាក្នុង ១ម៉ោងដោយគិតជាមធ្យមក្នុងសហគមន៍ (៣)ពេលវេលាដែលបានចំណាយនិងសេវាកម្មផ្នែកច្បាប់មានកំរិតច្រើនហួសហេតុ (៤)ឬមេធាវីរបស់មាតាបិតាមិនបានផ្តល់ឲ្យ LEA នូវការបណ្តឹងតវ៉ារឿងក្តីដែលសមរម្យមួយ។

ថ្លៃឈ្នួលមេធាវីអាចត្រូវបដិសេធបើសិនជាលោកអ្នកមិនព្រមទទួលយកនូវការសុំសំរបសំរួលដែលសមហេតុសមផលមួយពីក្រសួងអប់រំឬអង្គការសាធារណៈដប់ថ្ងៃ(១០)មុននឹងសវនាការចាប់ផ្តើមឡើងហើយនិងការសំរេចលើសវនាការនេះមិនប្រសើរជាងលើការសុំសំរបសំរួលនេះ។ ច្បាប់អប់រំ (20 USC 1415 [i} {3} [B]-[G]; 34 CFR 300.517)។ ថ្វីបើមានលក្ខខ័ណ្ឌយ៉ាងនេះក្តី ការឲ្យចេញថ្លៃមេធាវីនិងថ្លៃឈ្នួលផ្សេងៗទៀតដែលទាក់ទងនឹងរឿងក្តីអាចត្រូវផ្តល់ឲ្យបើលោកអ្នកជាមាតាបិតាឈ្នះរឿងក្តីហើយតុលាការរកឃើញថាលោកអ្នកមានហេតុផលត្រឹមត្រូវក្នុងការបដិសេធការសុំសំរបសំរួលនេះ។

ថ្លៃមេធាវីអាចនឹងមិនត្រូវបានផ្តល់ជូនដល់មេធាវីដែលចូលរួមកិច្ចប្រជុំក្រុម IEP លើកលែងតែកិច្ចប្រជុំនោះត្រូវបានកោះហៅដោយសារមានរឿងក្តី ផ្នែករដ្ឋបាល ឬត្រូវដោះស្រាយនៅមុខតុលាការ។ ការប្រជុំដោះស្រាយជំទាស់មិនចាត់ទុកថាជាការប្រជុំមួយដែលជាលទ្ធផលរបស់រឿងក្តីផ្នែករដ្ឋបាល ឬដោះស្រាយនៅមុខតុលាការ ហើយក៏មិនចាត់ទុកថាជា រឿងក្តី ផ្នែករដ្ឋបាល ឬត្រូវដោះស្រាយនៅមុខតុលាការសម្រាប់ការទូទាត់ថ្លៃមេធាវីដែរ។

### *តើកូនរបស់ខ្ញុំមានសិទ្ធិអ្វីខ្លះ នៅពេលដែល LEA កំពុងពិចារណាដាក់វិន័យលើរូបគេ ?*

មុនពេលដែលសិស្សមានពិការភាពត្រូវបានបញ្ឈប់ពីការសិក្សាពីសាលាក្នុងរយៈពេលលើសពី១០ថ្ងៃ ឬ១០ថ្ងៃបន្តបន្ទាប់គ្នានៃការបញ្ឈប់នេះជាលទ្ធផលនៃបំលាស់ប្តូរនៃកំរិតសិក្សារបស់ក្មេង LEA នឹងបើកការប្រជុំក្រុម IEP មួយដើម្បីកំណត់ថាតើសកម្មភាពរបស់ក្មេង ដែលនាំឲ្យមានវិធានការណ៍វិន័យគឺស្តែងចេញភាពមិនពេញលក្ខណៈរបស់ក្មេងឬទេ។ ក្រុម IEP នឹងកំណត់ថាតើឥរិយាបទដែលកំពុងចោទនោះត្រូវបាន (១)បង្កឡើងឬមានទំនាក់ទំនងដោយផ្ទាល់និងជិតស្និទ្ធជាមួយភាពមិនពេញលក្ខណៈរបស់កូនអ្នកឬទេ ឬ(២) ជាលទ្ធផលផ្ទាល់ដែល LEA ខកខានអនុវត្តតាមគោលការណ៍ IEP របស់សិស្សឬយ៉ាងណា ។ ក្នុងករណីពិសេស កូនរបស់លោកអ្នកអាចនឹងត្រូវដកចេញពីការអប់រំរបស់គេមិនឲ្យលើសពី៤៥ថ្ងៃសិក្សា។ មន្ត្រីសាលាមិនត្រូវបានហាមឃាត់ដោយច្បាប់អប់រំពិសេសឡើយ ក្នុងការរាយការណ៍អំពីបទល្មើសដែលប្រព្រឹត្តដោយកូនរបស់លោកអ្នកទៅដល់អជ្ញាធរ។

មាតាបិតាមានសិទ្ធិប្តឹងតវ៉ាចំពោះការសំរេចណាមួយស្តីពីការបញ្ឈប់ឬការដកសិស្សចេញពីកម្មវិធីអប់រំពិសេស។ នៅពេលដែលពាក្យបណ្តឹងមួយត្រូវបានធ្វើឡើងទាក់ទងនឹងការដាក់វិន័យឲ្យសិស្សស្ថិត ក្នុងកំរិតសិក្សាណាមួយឬទាក់ទងនឹងលទ្ធផលនៃកិច្ចប្រជុំកំណត់ពីសភាពរបស់សិស្ស រដ្ឋនឹងរៀបចំជំរុញឲ្យមានដំណើរការសវនាការបានឆាប់រហ័ស ដែលនឹងធ្វើឡើងក្នុងកំឡុងពេល២០ថ្ងៃសិក្សា បន្ទាប់ពីថ្ងៃដែលសវនាការនេះត្រូវបានស្នើសុំ រួចចេញនូវការកំណត់មួយក្នុងកំឡុងពេល១០ ថ្ងៃសិក្សាបន្ទាប់ពីការបញ្ចប់នៃសវនាការ ។ កូនរបស់អ្នកមាន

សិទ្ធិរៀនក្នុងកម្មវិធីសិក្សាដដែល ទៅតាមលក្ខន្តិកៈ “stay put” ក្នុងកំឡុងពេលនៃការប្តឹងត៍វ៉ា។ ប៉ុន្តែប្រសិនបើកូនរបស់អ្នកត្រូវបានដាក់ឲ្យស្ថិតនៅក្នុង IAES សំរាប់រយៈពេល ៤៥ថ្ងៃ ការដាក់នេះនឹងរក្សាឲ្យនៅដដែលដើម្បីរង់ចាំការសំរេចពីមន្ត្រីសវនាការ ឬរហូតដល់ការផុតកំណត់នៃការបញ្ឈប់ឲ្យរៀនជាបណ្តោះអាសន្ន អាស្រ័យលើស្ថានការណ៍ណាមួយកើតឡើងមុនគេ ។

ប្រសិនបើមានការស្នើសុំឲ្យមានការស្ទង់ប្រមាណលើក្មេង ក្នុងខណៈពេលដែលវិធានការណ៍វិន័យកំពុងរង់ចាំការសំរេច ការស្ទង់ប្រមាណនឹងត្រូវបានធ្វើឡើងឲ្យបានឆាប់រហ័ស។ នៅពេលកំពុងទទួលការស្ទង់ប្រមាណ ក្មេងនឹងត្រូវរក្សាឲ្យរៀនក្នុងកម្មវិធីសិក្សាបច្ចុប្បន្ន ដូចដែលបានកំណត់ដោយអាជ្ញាធរសាលា។

ក្មេងណាម្នាក់ ដែលពីមុនត្រូវបានគេចាត់ទុកថាមិនមានតំរូវការផ្នែកអប់រំពិសេសនិងសេវាកម្មដទៃៗទៀតទេនោះអាចនឹងទទួលបានការការពារដែលបានផ្តល់ឲ្យក្រោមច្បាប់ IDEA ប្រសិនបើ LEA បានទទួលដឹងឮថាក្មេងរូបនោះគឺជាក្មេងមិនមានលក្ខណៈគ្រប់គ្រាន់តាំងតែពីមុនពេលគេប្រព្រឹត្តសកម្មភាពដែលនាំឲ្យមានការដាក់វិន័យមក ។ ការដឹងឮអ្វីមួយអាចចាត់ទុកថាកើតមានឡើង បើ (១)មាតាបិតាបានបញ្ជាក់ក្នុងលិខិតដែលផ្ញើទៅបុគ្គលិកត្រួតពិនិត្យឬបុគ្គលិករដ្ឋបាលនៃក្រសួងអប់រំ ឬគ្រូរបស់ក្មេង ថាក្មេងនោះមានតំរូវការផ្នែកអប់រំពិសេសនិងសេវាកម្មដទៃៗទៀត (២)មាតាបិតាបានស្នើសុំឲ្យមានការស្ទង់ប្រមាណចំពោះក្មេង (៣)បុគ្គលិកសាលាបានបង្ហាញទៅដល់ប្រធានផ្នែកអប់រំពិសេសរបស់LEA ឬទៅដល់បុគ្គលិកត្រួតពិនិត្យដទៃៗទៀត អំពីកង្វល់ជាក់ច្បាស់ស្តីពីឥរិយាបថដែលបង្ហាញចេញដោយក្មេងនោះ ។ LEA មិនត្រូវបានចាត់ទុលថាមានការដឹងឮអ្វីទេ ក្នុងករណីដែលមាតាបិតាមិនអនុញ្ញាតិឲ្យមានការស្ទង់ប្រមាណលើក្មេង ឬ បានបដិសេដសេវាកម្មអប់រំពិសេស ឬក្នុងករណីដែលក្មេងបានទទួលការស្ទង់ប្រមាណដែរ ប៉ុន្តែត្រូវបានគេកំណត់ថាក្មេងនោះមិនមានតំរូវការសេវាកម្មផ្សេងៗនោះ ។ ប្រសិនបើទីភ្នាក់ងារមិនបានដឹងពីពិការភាពរបស់ក្មេងទេនោះ ក្មេងនោះនឹងមិនទទួលបានការការពារផ្នែកសវនាការរឿងក្តីរបស់ IDEA ឡើយ ។

### *តើមាននីតិវិធីអ្វីខ្លះ នៅពេលដែលកូនខ្ញុំអាចនឹងត្រូវដាក់ឲ្យរៀនក្នុងកម្មវិធីសិក្សាផ្លូវផ្សេងជាបណ្តោះអាសន្នមួយ IAES ?*

IAES គឺជាការដាក់ឲ្យរៀននៅក្នុងស្ថានភាពសិក្សា ឬកម្មវិធីអ្វីមួយផ្សេងទៀត ឬការបញ្ឈប់ឲ្យរៀនជាបណ្តោះអាសន្ន ដែលអាចបញ្ជាមកពីបុគ្គលិកសាលា ក្នុងរយៈពេលមិនឲ្យលើលពី១០ថ្ងៃសិក្សា (ដូចគ្នាទៅនឹងករណីរបស់សិស្សដែលពុំមានពិការភាពដែរ)។ ការសំរេចឲ្យដាក់សិស្សនៅក្នុង IAES អាចនឹងត្រូវធ្វើឡើងដោយក្រុម IEP នៅពេលដែលវិធានការណ៍វិន័យត្រូវបានថ្លឹងថ្លែងដោយ LEA ហើយនោះ ។

ក្នុងករណីពិសេស IAES អាចនឹងត្រូវបានរៀបចំឲ្យមានឡើងក្នុងរយៈពេលមិនឲ្យលើសពី៤៥ថ្ងៃ នៅពេលដែលមានក្មេងណាម្នាក់បានប្រព្រឹត្តបទល្មើសណាមួយនៅសាលាដូចពណ៌នាខាងក្រោម ទាំងនៅក្នុងបរិវេណសាលានិងគ្រឹះស្ថានអប់រំណាមួយដែលស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋឬ LEA ដូចជាៈ (១)កាន់ឬមានអាវុធ (២)មានឬប្រើប្រាស់ថ្នាំញៀនខុសច្បាប់ ឬលក់ឬសុំទិញសារធាតុហាមឃាត់ (៣)ធ្វើឲ្យនរណាម្នាក់មានរបួសរាងកាយធ្ងន់ធ្ងរ។ ប្រសិនបើ LEA មិនទាន់បានធ្វើទេនោះ បន្ទាប់ពីដាក់សិស្សឲ្យស្ថិតក្នុង IAES ចំនួន៤៥ថ្ងៃសិក្សា LEA នឹងធ្វើការស្ទង់ប្រមាណលើអាកប្បកិរិយា និងធ្វើផែនការអន្តរាគមន៍ផ្នែកអកប្បកិរិយា(ប្រសិនបើមិនទាន់បានធ្វើ)។ ប្រសិនបើផែនការអន្តរាគមន៍នេះត្រូវបានរៀបចំរួចរាល់ ក្រុម IEP នឹងពិចារណាលើការកែផែនការនេះ។ IEAS នឹងទទួលបានការបញ្ជាក់ពីក្រុម IEP ថាតើត្រូវបន្តឲ្យក្មេងរៀនក្នុងកម្មវិធីសិក្សាធម្មតាឬទេ និងថាតើក្មេងអាចទទួលបានសេវាកម្មនិងការកែសំរួលផ្សេងៗបន្ថែមពីលើសេវាកម្មនិងការកែសំរួលដែលមានស្រាប់ក្នុង IEP បច្ចុប្បន្នរបស់ក្មេងឬទេ ដើម្បីឲ្យសំរេចតាមគោលដៅរបស់ IEPផង និងឲ្យមានការកែសំរួលបន្ថែមឆ្លើយតបទៅនឹងសកម្មភាពល្មើសនោះផង។

នៅក្រោមច្បាប់សហព័ន្ធ មន្ត្រីសវនាការនឹងឲ្យក្មេងមានពិការភាពត្រលប់ទៅកម្មវិធីសិក្សាដែលរូបគេត្រូវបានដកចេញ ឬរៀបចំផ្លាស់ប្តូរឲ្យក្មេងមានពិការភាពស្ថិតក្នុង IEAS ដ៏សមស្របមួយ ក្នុងរយៈពេលមិនឲ្យលើសពីរយៈពេល៤៥ថ្ងៃសិក្សាពេលដែលមន្ត្រីសវនាការរកឃើញថាការអនុញ្ញាតិឲ្យក្មេងរៀនក្នុងកម្មវិធីបច្ចុប្បន្ននឹងធ្វើឲ្យមានគ្រោះថ្នាក់ដល់រូបគេនិងក្មេងដទៃទៀត។

នៅពេលដែលមានការសំរេចដាក់ឲ្យក្មេងស្ថិតក្នុង IEAS មាតាបិតារបស់សិស្សមានសិទ្ធិទទួលបានការជូនដំណឹងអំពីការសំរេចនេះព្រមទាំងទទួលបានលិខិតជាលាយល័ក្ខអក្សរស្តីពីនីតិវិធីបង្ការទាំងឡាយរបស់ IDEA ផ្នែកវិន័យ ។ ប្រសិនបើការដាក់ឲ្យក្មេងស្ថិតក្នុង IEAS មានរយៈពេលលើសពី១០ថ្ងៃសិក្សា ក្រុម IEP ត្រូវតែកំណត់ឲ្យមានការរៀបចំដ៏សមស្របនិងបណ្តាសេវាកម្មចាំបាច់ទាំងឡាយ ដើម្បីឲ្យក្មេងបន្តទទួលបានផលប្រយោជន៍ផ្នែកអប់រំ ។

### *តើមានច្បាប់វិន័យអ្វីខ្លះដែលទាក់ទងទៅនឹងការសំរេចចិត្តជាឯកតោភាគីរបស់ខ្ញុំ ក្នុងការឲ្យកូនខ្ញុំរៀននៅសាលាឯកជន ?*

ការសងប្រាក់ដល់មាតាបិតាដែលឲ្យកូនរៀននៅសាលាឯកជន អាចនឹងត្រូវសំរេចឡើងដោយមន្ត្រីសវនាការ ឬតុលាការនៅពេលដែលគេដឹងថា LEA មិនអាចផ្តល់ FAPE ដល់ក្មេងឲ្យបានទាន់ពេលវេលាមុនពេលចុះឈ្មោះចូលរៀនសាលាឯកជននោះ និងនៅពេលដែលគេដឹងថាការឲ្យក្មេងទៅរៀននៅសាលាឯកជនគឺជាការសមស្របមួយ។ ប្រាក់សំណងអាចនឹងត្រូវកាត់បន្ថយក្នុងករណីដែលមាតាបិតាមិនបានជូនដំណឹងដល់ IEP អំពីការបដិសេធរបស់គាត់ក្នុងការមិនយល់ស្របក្នុងការដាក់ឲ្យកូនគាត់រៀននៅក្នុងកម្មវិធីសិក្សាណាមួយដែលបានស្នើឡើង និងក្នុងករណីមាតាបិតាខកខានជូនដំណឹងអំពីគោលបំណងរបស់ខ្លួនក្នុងការឲ្យកូនទៅរៀននៅសាលាឯកជនក្រោមការចំណាយរបស់រដ្ឋ នៅក្នុងការប្រជុំ IEP លើកចុងក្រោយគេ និងយ៉ាងហោចណាស់ឲ្យបាន១០ថ្ងៃ មុនការដកក្មេងចេញពីសាលារដ្ឋ។ ប្រាក់សំណងក៏អាចនឹងត្រូវកាត់បន្ថយផងដែរ ក្នុងករណីមុនពេលដកក្មេងពីសាលារដ្ឋ IEP បានជូនដំណឹងដល់មាតាបិតាអំពីគោលបំណងរបស់ IEP ក្នុងការស្ទង់ប្រមាណលើក្មេង ខណៈពេលដែលមាតាបិតាមិនព្រមឲ្យកូនទទួលការស្ទង់ប្រមាណនោះ។

ប្រាក់សំណងមិនអាចកាត់បន្ថយបានទេ ប្រសិនបើ LEA រារាំងមាតាបិតាពីការផ្តល់ជាពត៌មាន ឬមាតាបិតាមិនទទួលបានការជូនដំណឹងស្តីពីតំរូវការផ្សេងៗក្នុងលិខិតជូនដំណឹងជាលាយល័ក្ខអក្សររបស់គាត់ ឬក្នុងករណីដែលការធ្វើតាមតំរូវការដែលមានក្នុងលិខិតជូនដំណឹងនេះអាចនឹងធ្វើឲ្យមានការប៉ះពាល់មិនល្អដល់រាងកាយរបស់ក្មេង។ ចំនួនប្រាក់សំណងអាចនឹង ឬមិនត្រូវបានកាត់បន្ថយ ប្រសិនបើមាតាបិតាជាអ្នកមិនចេះអក្សរ និងមិនអាចសរសេរជាភាសាអង់គ្លេស ឬក្នុងករណីដែលការធ្វើតាមតំរូវការដែលមានក្នុងលិខិតជូនដំណឹងនេះ អាចនឹងធ្វើឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់សតិអារម្មណ៍របស់ក្មេង។

### *តើអ្វីខ្លះទៅជាសាលាពិសេសរបស់រដ្ឋ ?*

សាលាពិសេសរបស់រដ្ឋផ្តល់សេវាកម្មដល់សិស្សដែលថ្លង់ ស្តាប់មិនសូវឮ ខ្វាក់ មើលសូវមិនឃើញ ឬថ្លង់និងខ្វាក់ នៅតាមសាលាមួយក្នុងចំណោមសាលាទាំងបីៈ The California School for Deaf នៅ Fremont និង Riverside ហើយនិងនៅ California School for the Blind នៅ Fremont ។ កម្មវិធីស្នាក់នៅនឹងសាលានិងកម្មវិធីពេញមួយថ្ងៃមានផ្តល់ឲ្យសិស្សពីទារកទៅដល់អាយុ២១ឆ្នាំនៅសាលារដ្ឋទាំងពីរសម្រាប់សិស្សថ្លង់ និងពីអាយុប្រាំឆ្នាំដល់អាយុ២១ឆ្នាំនៅសាលា California School for the Blind ។ សាលាពិសេសរបស់រដ្ឋក៏មានធ្វើការស្ទង់ប្រមាណនិងជំនួយបច្ចេកទេសផងដែរ។ ដើម្បីព័ត៌មានបន្ថែមអំពីសាលាពិសេសរបស់រដ្ឋ សូមចូលទៅគេហទំព័ររបស់ក្រសួងអប់រំប្រចាំរដ្ឋកាលីហ្វ័រនីញ៉ា គឺ http://www.cde.ca.gov/sp/ss/ ឬសួរសំនួរថែមទៀតពីសមាជិកនៅក្នុងក្រុម IEP របស់កូនលោកអ្នក ឬទាក់ទងការិយាល័យ SELPA ។

### *តើក្រោមស្ថានការណ៍បែបណាខ្លះ ទើបធ្វើឲ្យមានកាតែងតាំងមាតាបិតាតំណាង ?*

ក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់ពីមានការកំណត់របស់ទីភ្នាក់ងារប្រចាំមូលដ្ឋាន ដែលថាសិស្សណាម្នាក់ស្ថិតក្នុងការត្រូវការឲ្យមានមាតាបិតាតំណាង LEA នឹងតែងតាំងមាតាបិតាតំណាងសំរាប់ក្មេង ប្រសិនបើៈ

១. ក្មេងស្ថិតនៅក្រោមការការពាររបស់តុលាការព្រោះតុលាការបានដាក់ដែនកំណត់ទៅលើសិទ្ធិរបស់មាតាបិតាឬអាណាព្យាបាលក្នុងការសំរេចចិត្តផ្នែកអប់រំសំរាប់ក្មេង ***និង*** ក្មេងរូបនោះមិនមានមាតាបិតាឬអាណាព្យាបាលទទួលខុសត្រូវដើម្បីតំណាងឲ្យរូបគេឬ

២. ក្មេងមិនស្ថិតនៅក្រោមការការពាររបស់តុលាការ ***និង*** គ្មានមាតាបិតានិងអាណាព្យាបាល ***ឬ*** ក្មេងគ្មានអ្នកថែរក្សា ***ឬ*** ជាយុវជនឯកកោគ្មានផ្ទះសំបែង ។

ក្នុងការកំណត់ថានរណានឹងដើរតួជាមាតាបិតាតំណាងរបស់ក្មេង ប្រសិនបើមានក្រុមមនុស្សដូចជា អ្នកថែទាំដែលត្រូវជាសាច់ញាតិនឹងក្មេង ឪពុកម្តាយចិញ្ចឹម ឬអ្នកជំនួយពិសេសតែងតាំងដោយតុលាការ SELPA នឹងធ្វើការពិចារណាទៅលើអ្នកទាំងនេះ បើមិនដូច្នោះទេ SELPA

នឹងធ្វើការតែងតាំងបុគ្គលម្នាក់ដោយខ្លួនឯង ។ មាតាបិតាតំណាងគឺជាបុគ្គលម្នាក់ដែលមានចំណេះដឹងនិងជំនាញគ្រប់គ្រាន់ក្នុងការតំណាងឲ្យក្មេង។ មាតាបិតាតំណាងរបស់ក្មេងត្រូវជួបជាមួយក្មេងយ៉ាងហោចណាស់ម្តង និងគួរតែចេះទំនាក់ទំនងនឹងក្មេងតាមផ្លូវគំនិត លើកលែងតែបុគ្គលនោះមិនមានពេលវេលាគ្រប់គ្រាន់ ។

មាតាបិតាតំណាងនឹងតំណាងឲ្យក្មេងទៅលើបញ្ហាទាក់ទង អត្តសញ្ញាណបកម្ម ការស្ទង់ប្រមាណ ការបង្កើតនិងរៀបចំផែនការបង្រៀន ការមើលឡើងវិញនិងកែសំរួល IEP និងបញ្ហាដទៃៗទៀតដែលទាក់ទងនឹងការផ្តល់ FAPE សំរាប់ក្មេងដោយរួមទាំងការសរសេរជាលិខិតយល់ព្រមទទួលយក IEP ផ្នែកសេវាកម្មសុខភាពបំរុង សេវាកម្មព្យាបាលជំងឺផ្លូវសតិអារម្មណ៍ និងសេវាកម្មអប់រំពង្រឹងរាងកាយ។

បណ្តាបុគ្គលដែលមានជំលោះរឿងផលប្រយោជន៍ក្នុងការតំណាងឲ្យក្មេង នឹងមិនត្រូវបានតែងតាំងជាមាតាបិតាតំណាងឡើយ ។ ជំលោះនឹងកើតមានប្រសិនបើមាតាបិតាតំណាងគឺជាបុគ្គលិក LEA ដែលពាក់ព័ន្ធនឹងការអប់រំឬចិញ្ចឹមថែទាំក្មេងដែលមានប្រភពចំណូលពីការថែទាំក្មេងរូបនេះឬក្មេងដទៃទៀត ។ នៅពេលដែលគ្មានជំលោះផលប្រយោជន៍ អ្នកចិញ្ចឹមថែទាំក្មេង គ្រូបង្រៀនចូលនិវត្តន៍ អ្នកធ្វើការខាងសង្គមកិច្ច និងភ្នាក់ងារតម្រួតល្បងទាំងអស់អាចនឹងធ្វើជាមាតាបិតាតំណាងបាន ។ ក្នុងករណីដែលក្មេងជាយុវជនឯកកោគ្មានទីលំនៅ បុគ្គលិកមកពីអង្គការផ្តល់ជំរកបន្ទាន់បណ្តោះអាសន្ន កម្មវិធីរស់នៅដោយមិនពឹងពាក់លើគេ និង បុគ្គលិកមកពីកម្មវិធីប្រមូលក្មេងតាមចិញ្ចឹមផ្តល់អាចនឹងត្រូវបានតែងតាំងជាមាតាបិតាតំណាងជាបណ្តោះអាសន្ន ដោយមិនគិតពីករណីជំលោះដែលអាចកើតមានដូចរៀបរាប់ខាងលើឡើយ រហូតទាល់តែគេរកបានមាតាបិតាតំណាងម្នាក់ផ្សេងទៀតដែលមានលក្ខណៈសម្បត្តិត្រឹមត្រូវ។

ម៉្យាងវិញទៀត មាតាបិតាតំណាងអាចនឹងត្រូវបានតែងតាំងដោយចៅក្រមដែលត្រួតពិនិត្យលើការថែទាំក្មេង (ផ្សេងក្រៅពី LEA) ក្នុងលក្ខខ័ណ្ឌដែលមាតាបិតាតំណាងរូបនោះបានបំពេញរាល់តំរូវការ ដូចដែលបានរៀរាប់ខាងលើ។